# អនុសញ្ញាស្តីពីសិទ្ធិកុមារ

## និងពិធីសារបន្ថែម



អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស – ការិយាល័យប្រចាំកម្ពុជា

unicef

# អនុសញ្ញា

## ស្តីពី

# សិទ្ធិកុមារ និងពិធីសារបន្ថែម

ខែមិថុនា ឆ្នាំ២០០៩

រូបភាពក្រមដោយ ថៅ វ៉ាសូកា - យូនីសេហ្វនៅកម្ពុជា

នេះគឺជាការបោះពុម្ពផ្សាយរួមគ្នា ដោយមូលនីធិសហប្រជាជាតិដើម្បីកុមារ (យូនីសេហ្វ) និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស


អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំកម្ពុជា - ភ្នំពេញ

unicef

# មាតិកា

១- សេចក្តីផ្តើមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម.................................ទំព័រ៧

២- អនុសញ្ញាស្តីពីសិទ្ធិកុមារ..................ទំព័រ១៤

៣- ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ...........................ទំព័រ៥៣

៤- ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការលក់កុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ..........ទំព័រ៦៥

# អនុសញ្ញាស្តីពីសិទ្ធិកុមារ
# និងពិធីសារបន្ថែម

## សេចក្តីផ្តើម

អនុសញ្ញាស្តីពីសិទ្ធិកុមារគឺជាសន្ធិសញ្ញាអន្តរជាតិដែលមានចែងពីបទដ្ឋានអប្បបរមាជាសកល និងពីគោលការណ៍សីលធម៌សំរាប់ការប្រព្រឹត្តលើកុមារនៅក្នុងសង្គម។ អនុសញ្ញានេះ គឺជាសេចក្តីថ្លែងលំអិតមួយពីសិទ្ធិទាំងឡាយដែលកុមារគ្រប់ទិសទីត្រូវទទួលបាន ហើយរួមបញ្ចូលសិទ្ធិពលរដ្ឋ នយោបាយសង្គម សេដ្ឋកិច្ច និងវប្បធម៌ដែលពាក់ព័ន្ធនឹងកុមារ ។

នៅក្នុងអតីតកាល កុមារត្រូវបានគេចាត់ទុកគ្រាន់តែជាអ្នករងអំពើ ឬកម្មវត្ថុដែលគេប្រព្រឹត្តទៅលើប៉ុណ្ណោះ។ ប៉ុន្តែឥឡូវនេះ អនុសញ្ញាស្តីពីសិទ្ធិកុមារទទួលស្គាល់កុមារថាជាមនុស្សដែលមានសិទ្ធិរបស់គេផ្ទាល់ គឺជាសិទ្ធិដែលគេទទួលបានអាស្រ័យដោយគេកើតជាមនុស្ស។ កុមារអាចទាមទារសិទ្ធិរបស់ខ្លួនពីអ្នកមានភារកិច្ចនានា ដូចជាឪពុក-ម្តាយ និងរដ្ឋ ជាពិសេសមន្ត្រីនគរបាល និងតុលាការដែលមានភារកិច្ចគោរព ការពារ និងបំពេញតាមសិទ្ធិរបស់កុមារ ។

ដូចសិទ្ធិមនុស្សទាំងអស់ដែរ សិទ្ធិកុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារមិនអាចបំបែកចេញពីគ្នាបានទេ។ នេះមានន័យថាសិទ្ធិទាំងអស់មានទំនាក់ទំនងគ្នា ហើយពុំមានសិទ្ធិណាមួយសំខាន់ជាងសិទ្ធិណាមួយឡើយ។ ទោះយ៉ាងណាក៏ដោយ អនុសញ្ញាស្តីពីសិទ្ធិកុមារ យកចិត្តទុកដាក់ចំពោះភាពខុសគ្នា

នៃវប្បធម៌ នយោបាយនិងស្ថានភាពពិតខាងផ្នែកសំភារៈក្នុងចំណោមរដ្ឋនានា។ អ្វីដែលត្រូវយកមកពិចារណាជាចំបងបំផុតនោះគឺឧត្តមប្រយោជន៍របស់កុមារ។

អនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ គឺជាថ្ងៃដែលប្រារព្ធដោយសហប្រជាជាតិធ្វើជាទិវាកុមារសកល។*

ព្រះរាជាណាចក្រកម្ពុជា បានចូលជារដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារនៅឆ្នាំ១៩៩២ ។ តាមរយៈការចូលជាភាគីនេះ ព្រះរាជាណាចក្រកម្ពុជា ប្តេជ្ញាខ្លួន ការពារ និងបំពេញតាមសិទ្ធិនានារបស់កុមារទាំងអស់នៅកម្ពុជា ។

## ហេតុអ្វីបានជាកុមារត្រូវការសិទ្ធិពិសេស ?

កុមារមានសិទ្ធិឱ្យគេប្រព្រឹត្តទៅលើ ដូចមនុស្សពេញវ័យដទៃទៀតដែរ ដើម្បីរស់នៅក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាព។ ក្នុងពេលជាមួយគ្នានេះដែរ កុមារក៏មានសិទ្ធិពិសេសបន្ថែម ដោយសារតែពួកគេមានវ័យក្មេង និងងាយរងគ្រោះ។ កុមារនឹងមិនអាចរស់រាន និងឈានដល់សក្តានុពលពេញលេញ បើគ្មានជំនួយ និងការសហការពីមនុស្សពេញវ័យ ។ គោលបំណងរបស់អនុសញ្ញាស្តីពីសិទ្ធិកុមារ គឺបង្កើតជាបទដ្ឋានសំរាប់ការពារកុមារប្រឆាំងនឹងការទុកចោលមិនយកចិត្តទុកដាក់ ការរំលោភបំពាន ការកេងប្រវ័ញ្ច និងការរើសអើងដែលខ្លួនជួបប្រទះ ក្នុងជីវិតផ្សេងៗ ជារៀងរាល់ថ្ងៃនៅគ្រប់ប្រទេស ។

* មហាសន្និបាតអង្គការសហប្រជាជាតិបានចាត់ទុកថ្ងៃ២០ វិច្ឆិកា ថាជាទិវាកុមារសកល នៅឆ្នាំ១៩៥៤។ សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ក៏ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃ២០ វិច្ឆិកាដែរ តែក្នុងឆ្នាំ១៩៥៩។ នៅកម្ពុជា ទិវាកុមារអន្តរជាតិ គឺប្រារព្ធធ្វើនៅរៀងរាល់ថ្ងៃ១ មិថុនា។

**កុមារជាអ្នកណា ?**

កុមារត្រូវគេទទួលស្គាល់ជាមនុស្សមានអាយុក្រោម ១៨ឆ្នាំ លើកលែងតែច្បាប់របស់ប្រទេស ចែងពីអាយុពេញវ័យដែលគេសន្មត់រហ័សជាង ។

**តើគោលការណ៍អ្វីខ្លះណែនាំសំរាប់ការអនុវត្តន៍អនុសញ្ញា ?**

អនុសញ្ញាស្តីពីសិទ្ធិកុមារមានចែងគោលការណ៍ណែនាំ៤ ហើយតាមរយៈនេះ សិទ្ធិកុមារត្រូវទទួលបានការការពារ ។ គោលការណ៍ទាំងនេះ រួមមាន:

**១-ឧត្តមប្រយោជន៍កុមារ (មាត្រា៣)**

គ្រប់សកម្មភាពពាក់ព័ន្ធនឹងកុមារ ត្រូវយកឧត្តមប្រយោជន៍របស់កុមារមកពិចារណាជាចំបង ។

**២-ការមិនរើសអើង (មាត្រា២)**

កុមារគ្រប់រូបត្រូវទទួលបានសិទ្ធិទាំងអស់របស់ខ្លួន ដោយមិនមានការរើសរើងនៃប្រភេទណាមួយទេ។ កុមារមិនអាចត្រូវបានគេបដិសេធសិទ្ធិរបស់ខ្លួនដោយសារតែជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈនយោបាយ ឬទស្សនៈផ្សេងៗ ជាតិ ប្រភពជនជាតិ ឬឋានៈក្នុងសង្គម ទ្រព្យសម្បត្តិ ពិការភាព កំណើត ឋានៈ ឬស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬឪពុក-ម្តាយរបស់កុមារនោះទេ ។

**៣-សិទ្ធិមានជីវិត សិទ្ធិរស់រានមានជីវិត និងសិទ្ធិអភិវឌ្ឍន៍ (មាត្រា ៦)**

កុមារគ្រប់រូប មានសិទ្ធិមានជីវិតតាំងពីកំណើត។ រដ្ឋត្រូវធានាពីការរស់រានមានជីវិត និងការអភិវឌ្ឍន៍របស់កុមារ ឱ្យមានកំរិតអតិបរមាតាមដែលអាចធ្វើបាន។

**៤-ការគោរពទស្សនៈកុមារ (មាត្រា១២)**

កុមារដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួន មានសិទ្ធិបញ្ចេញមតិរបស់គេ ដោយសេរី ក្នុងគ្រប់បញ្ហាពាក់ព័ន្ធនឹងខ្លួនគេ។ ទស្សនៈកុមារត្រូវតែបានគេយកទៅពិចារណាថ្លឹងថ្លែង ឱ្យបានសមស្របទៅតាមអាយុ និងការយល់ដឹង (ភាពចាស់ចិត្តចាស់គំនិត) របស់កុមារ ។

## តើសិទ្ធិជាក់លាក់អ្វីខ្លះដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ?

អនុសញ្ញាមានចែងជាបួនប្រភេទធំៗនៃសិទ្ធិកុមារៈ

**១-សិទ្ធិរស់រានមានជីវិតៈ** សិទ្ធិនេះរួមបញ្ចូល សិទ្ធិមានជីវិត និងសិទ្ធិទទួលបានការថែទាំសុខភាព និងវេជ្ជសាស្ត្រក្នុងកំរិតខ្ពស់បំផុត ។

**២-សិទ្ធិអភិវឌ្ឍន៍ៈ** សិទ្ធិទាំងនេះរួមបញ្ចូលអ្វីទាំងអស់ដែលកុមារត្រូវការដើម្បីលូតលាស់ក្នុងកំរិតខ្ពស់បំផុត និងដើម្បីឱ្យក្លាយទៅជាសមាជិកដែលទទួលខុសត្រូវរបស់សង្គម ។ សិទ្ធិនេះ រួមមានការអប់រំគ្រប់ប្រភេទ និងសិទ្ធិទទួលបានជីវភាពរស់នៅគ្រប់គ្រាន់ សំរាប់ការលូតលាស់របស់កុមារ ផ្នែករាងកាយ សតិអារម្មណ៍ ស្មារតី សីលធម៌ និងសង្គម ។

**៣-សិទ្ធិទទួលបាននូវការការពារៈ** សិទ្ធិនេះចង់សំដៅយ៉ាងទូលាយដល់សិទ្ធិដែលត្រូវបានទទួលការការពារ រួចផុតពីអំពើ និងការប្រព្រឹត្តផ្សេងៗដែលបង្កអន្តរាយដល់កុមារ ។ សិទ្ធិនេះ រួមមានការការពារពីការរើសអើង ពីការរំលោភបំពាន ការទុកចោលមិនយកចិត្តទុកដាក់ និងការកេងប្រវ័ញ្ច ការការពារកុមារដែលគ្មានគ្រួសារ និងការការពារកុមារជាជនភៀសខ្លួន ។

**៤-សិទ្ធិចូលរួម៖** សិទ្ធិទាំងនេះ គ្របដណ្តប់លើសិទ្ធិរបស់កុមារក្នុងការចូលរួមបញ្ចេញមតិរបស់ខ្លួនក្នុងគ្រប់បញ្ហា និងត្រូវបានគេទទួលស្តាប់ក្នុងគ្រប់សេចក្តីសំរេចដែលប៉ះពាល់ដល់អាយុជីវិតរបស់កុមារ ។ នៅពេលសមត្ថភាពរបស់កុមាររីវត្តឡើង កុមារគួរតែមានឱកាសកាន់តែច្រើនជាងមុន ក្នុងការចូលរួមសកម្មភាពរបស់សង្គម ដើម្បីជាការរៀបចំសំរាប់ជីវិតជាមនុស្សពេញវ័យ។

**តើអនុសញ្ញាស្តីពីសិទ្ធិកុមារដាក់កាតព្វកិច្ចអ្វីខ្លះដល់រដ្ឋាភិបាល ?**

រដ្ឋភាគីនីមួយៗនៃអនុសញ្ញាសិទ្ធិកុមារត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

អនុម័តច្បាប់ គោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីធានាការអនុវត្តន៍ និងការទទួលបានសិទ្ធិដែលមានចែងក្នុងអនុសញ្ញាសិទ្ធិកុមារ (មាត្រា៤)

ចាត់វិធានការច្បាប់ រដ្ឋបាល និងវិធានការដទៃទៀតឱ្យបានសមស្របទៅនឹងកំរិតអតិបរមា នៃធនធានដែលមាន របស់ប្រទេសខ្លួន និងតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ ។ នេះមានន័យថាកំណត់អាទិភាព និងទុកកុមារជាចំបង (មាត្រា៤)

លើកកំពស់ការយល់ដឹង ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ (មាត្រា៤២)

បញ្ជូនរបាយការណ៍ស្តីពីស្ថានភាពបច្ចុប្បន្នរបស់កុមារ និងភាពរីកចំរើននៃការអនុវត្តន៍ អនុសញ្ញាស្តីពីសិទ្ធិកុមារ ទៅឱ្យគណៈកម្មាធិការសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិពីរឆ្នាំក្រោយពីការផ្តល់សច្ចាប័នលើអនុសញ្ញានេះ និងរៀងរាល់ ៥ឆ្នាំម្តង បន្តបន្ទាប់មកទៀត (មាត្រា៤៤)

**តើពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារមានអ្វីខ្លះ ?**

ពិធីសារបន្ថែម គឺជាឯកសារបន្ថែមលើសន្ធិសញ្ញាគោលដែលរដ្ឋនីមួយៗ

អាចជ្រើសរើសដើម្បីចូលជាសមាជិកប្រសិនបើរដ្ឋនោះយល់ព្រមទទួលកាតព្វកិច្ចបន្ថែមតាមពិធីសារនោះដោយមិនគិតដល់អនុសញ្ញាដើមឡើយ។

អនុសញ្ញាស្តីពីសិទ្ធិកុមារ មានពិធីសារបន្ថែមចំនួនពីរដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីខែឧសភា ឆ្នាំ២០០០ដូចគ្នា។ ពិធីសារមួយគឺសំដៅប្រឆាំងនឹងការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ឯពិធីសារបន្ថែមមួយទៀត គឺសំដៅដល់ការការពារកុមារពីការពាក់ព័ន្ធនៅក្នុងជំលោះប្រដាប់អាវុធ ដោយធ្វើការដាក់កំហិត និងបញ្ញាត្តិពីការប្រើប្រាស់ទាហានក្រោមអាយុ១៨ឆ្នាំ។

## តើអនុសញ្ញានេះអនុវត្តយ៉ាងដូចម្តេចនៅកម្ពុជា?

កម្ពុជាបានក្លាយជារដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ វិច្ឆិកា ១៩៩២ ជារដ្ឋភាគីនៃពិធីសារបន្ថែមប្រឆាំងនឹងការជួញដូរកុមារ នៅថ្ងៃទី៣០ មិថុនា ឆ្នាំ២០០២ និងជារដ្ឋភាគីនៃពិធីសារបន្ថែមស្តីពីការពាក់ព័ន្ធកុមារនៅក្នុងជំលោះប្រដាប់អាវុធនៅថ្ងៃទី១៦ សីហា ២០០៦ ។

មាត្រា៣១នៃរដ្ឋធម្មនុញ្ញធានាការពារអនុសញ្ញានេះ ជាមួយនឹងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដទៃទៀតថាជាផ្នែកមួយនៃច្បាប់កម្ពុជា។ មាត្រា៤៨ គូសបញ្ជាក់បន្ថែមទៀតថា "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។"

នៅក្នុងសេចក្តីសំរេចរបស់ខ្លួនកាលពីថ្ងៃទី១០-កក្កដា-២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញ ដែលជាស្ថាប័នមួយបង្កើតឡើង ដើម្បីការពាររដ្ឋធម្មនុញ្ញ បានគូស

បញ្ជាក់ជាថ្មី ពីការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ នៅក្នុងច្បាប់កម្ពុជា និងធ្វើការរំលឹកដល់ចៅក្រម ក្នុងការសំរេចក្តី និងធ្វើការបកស្រាយច្បាប់ ថា ចៅក្រមត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួនដល់បទបញ្ញត្តិនៃសន្ធិសញ្ញាដែលកម្ពុជាបាន ទទួលស្គាល់ រួមទាំងអនុសញ្ញាស្តីពីសិទ្ធិកុមារផង ។

## គណៈកម្មាធិការសិទ្ធិកុមារ

ដោយបានក្លាយខ្លួនជារដ្ឋភាគីនៃអនុសញ្ញា រដ្ឋនោះត្រូវធ្វើការប្តេជ្ញាចិត្ត ដោយភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ចំពោះប្រជាពលរដ្ឋរបស់ខ្លួន ជាពិសេសដល់កុមារ ព្រមទាំងសហគមន៍អន្តរជាតិ ពីការអនុវត្តបទបញ្ញត្តទាំងឡាយនៃអនុសញ្ញានេះ ដើម្បីលើកស្ទួយ និងការពារសិទ្ធិកុមារ។

យោងតាមអនុសញ្ញានេះ គណៈកម្មាធិការអន្តរជាតិមួយ ដែលមានអ្នក ជំនាញការឯករាជ្យ ហើយដែលគេស្គាល់ជាទូទៅថាគណៈកម្មាធិការសិទ្ធិកុមារ ត្រូវបានបង្កើតឡើង ដើម្បីតាមដានការវិវត្តន៍របស់រដ្ឋភាគី ក្នុងការបំពេញតាម ការប្តេជ្ញាចិត្តរបស់ខ្លួន។ គ្រប់រដ្ឋភាគី តំរូវឱ្យធ្វើរបាយការណ៍ជាទៀងទាត់តាម កាលកំណត់ជូនគណៈកម្មាធិការ ពីវិធានការដែលខ្លួនប្រកាន់យកដើម្បីអនុវត្ត អនុសញ្ញានេះ។

កម្ពុជាបានធ្វើរបាយការណ៍ចំនួនពីរលើករួចមកហើយជូនគណៈកម្មាធិការ។ រាជរដ្ឋាភិបាលកម្ពុជា បានដាក់របាយការណ៍តាមកាលកំណត់លើកទីពីររបស់ខ្លួន ជូនគណៈកម្មាធិការ កាលពីខែកុម្ភៈ ឆ្នាំ២០០៩ ហើយគណៈកម្មាធិការនឹង ពិនិត្យរបាយការណ៍នេះ នៅពេលណាមួយក្នុងឆ្នាំ២០១០ ឬ២០១១។

# អនុសញ្ញាស្ដីពីសិទ្ធិកុមារ

ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងឱ្យសុំចូលជាសមាជិក

តាមសេចក្ដីសម្រេចចិត្តលេខ៤៤/២៥ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩

របស់មហាសន្និបាតអង្គការសហប្រជាជាតិ

ចូលជាធរមាននៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩០ ស្របតាមមាត្រា៤៩

# បុព្វកថា

## *រដ្ឋភាគីទាំងអស់នៃអនុសញ្ញានេះ*

*យល់ឃើញថា* យោងតាមគោលការណ៍នានាដែលប្រកាសក្នុងធម្មនុញ្ញសហប្រជាជាតិ ការទទួលស្គាល់សេចក្ដីថ្លៃថ្នូរជាប់ពីកំណើត និងសិទ្ធិស្មើភាព និងមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបាន របស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស ជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក។

*ចងចាំថា* ប្រជាជាតិនៃសហប្រជាជាតិបានប្រកាសបញ្ជាក់សារជាថ្មីក្នុងធម្មនុញ្ញសហប្រជាជាតិ នូវជំនឿរបស់ខ្លួន ទៅលើសិទ្ធិមូលដ្ឋានរបស់មនុស្ស លើសេចក្ដីថ្លៃថ្នូរ និងតម្លៃរបស់មនុស្ស ហើយប្ដេជ្ញាលើកស្ទួយវឌ្ឍនភាពសង្គម និងកម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង ក្នុងសេរីភាពកាន់តែទូលំទូលាយ ។

*ទទួលស្គាល់ថា* ក្នុងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិនានាស្ដីពីសិទ្ធិមនុស្ស សហប្រជាជាតិបានប្រកាស និងយល់ស្របថា មនុស្សគ្រប់រូបត្រូវមានសិទ្ធិ និងសេរីភាពទាំងអស់ ដូចមានចែងនៅ

ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយឬមតិផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពផ្សេងទៀតឡើយ។

*រំលឹកឡើងវិញថា* ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សហប្រជាជាតិបានប្រកាសថា កុមារមានសិទ្ធិទទួលជំនួយ និងការថែទាំពិសេស។

*ជឿជាក់ថា* គ្រួសារជាអង្គភាពគ្រឹះនៃសង្គម និងជាមជ្ឈដ្ឋានធម្មជាតិសម្រាប់ការរីកលូតលាស់ និងសុខុមាលភាពនៃសមាជិកទាំងអស់របស់សង្គម និងជាពិសេស កុមារត្រូវទទួលនូវការការពារ និងជំនួយឧបត្ថម្ភចាំបាច់ ដើម្បីឱ្យគ្រួសារអាចរ៉ាប់រងការទទួលខុសត្រូវរបស់ខ្លួនពេញលេញនៅក្នុងសហគមន៍។

*ទទួលស្គាល់ថា* ដើម្បីឱ្យមានការអភិវឌ្ឍន៍ពេញលេញ និងសមស្របតាមបុគ្គលិកលក្ខណៈរបស់កុមារ កុមារត្រូវធំលូតលាស់ក្នុងមជ្ឈដ្ឋានគ្រួសារ ក្នុងបរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និងការយោគយល់។

*យល់ឃើញថា* កុមារ គួរត្រូវបានគេរៀបចំឱ្យមានជីវភាពជាឯកត្តជនក្នុងសង្គម និងធំលូតលាស់ក្នុងស្មារតីនៃឧត្តមគតិ ដូចមានចែងក្នុងធម្មនុញ្ញសហប្រជាជាតិ និងជាពិសេស ក្នុងស្មារតីនៃសន្តិភាព សេចក្តីថ្លៃថ្នូរ ការអត់ឱនឱ្យគ្នា សេរីភាព សមភាព និងសាមគ្គីភាព ។

*ចងចាំថា* ភាពចាំបាច់ដើម្បីផ្តល់ការការពារពិសេសដល់កុមារ ត្រូវបានថ្លែងក្នុងសេចក្តីប្រកាស នាទីក្រុងហ្សឺណែវ ឆ្នាំ១៩២៤ ស្តីពីសិទ្ធិកុមារ និងក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិកុមារដែលបានអនុម័តដោយមហាសន្និបាតអង្គការ

សហប្រជាជាតិនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៥៩ ហើយភាពចាំបាច់នេះត្រូវបានទទួលស្គាល់ នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ជាពិសេសក្នុងមាត្រា២៣ និងមាត្រា២៤) ក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ជាពិសេសក្នុងមាត្រា១០) និងក្នុងលក្ខន្តិកៈ និងលិខិតុបករណ៍ពាក់ព័ន្ធនានារបស់ស្ថាប័នឯកទេស និងអង្គការអន្តរជាតិ ដែលមានកិច្ចការទាក់ទិននឹងសុខុមាលភាពរបស់កុមារ ។

*ចងចាំថា* ដូចបានបញ្ជាក់ក្នុងសេចក្តីប្រកាសស្តីពីសិទ្ធិកុមារ "ដោយសារភាពខ្ចីខាងផ្នែករាងកាយ និងសតិបញ្ញា កុមារត្រូវការនូវកិច្ចការពារ និងការថែទាំជាពិសេសរួមទាំងការការពារសមស្របតាមផ្លូវច្បាប់ទាំងមុននិងបន្ទាប់ពីកំណើត"

*រំលឹកឡើងវិញថា* បទប្បញ្ញត្តិនៃសេចក្តីប្រកាសស្តីពីគោលការណ៍ខាងសង្គមកិច្ច និងខាងផ្លូវច្បាប់ទាក់ទងនឹងកិច្ចការពារ និងសុខុមាលភាពរបស់កុមារ សំដៅជាពិសេសទៅរកការទុកដាក់ជាមួយឪពុក-ម្តាយធម៌ និងសុំកូនក្នុងប្រទេស និងអន្តរជាតិ វិធានជាបទដ្ឋានអប្បបរមារបស់សហប្រជាជាតិដើម្បីគ្រប់គ្រងវិស័យយុត្តិធម៌សម្រាប់កុមារ (វិធានក្រុងប៉េកាំង) និងសេចក្តីប្រកាសស្តីពីការការពារស្ត្រី និងកុមារក្នុងពេលមានអាសន្ន និងជម្លោះប្រដាប់អាវុធ។

*ទទួលស្គាល់ថា* នៅក្នុងប្រទេសទាំងអស់លើពិភពលោកមានកុមារកំពុងរស់នៅក្នុងស្ថានភាពដ៏សែនលំបាក ហើយកុមារទាំងនោះ ត្រូវការនូវការយកចិត្តទុកដាក់ពិសេស ។

*យកមកគិតនូវ* សារសំខាន់នៃប្រពៃណី និងតម្លៃវប្បធម៌របស់ប្រជាជាតិនីមួយៗក្នុងការការពារ និងការរីកចម្រើនដោយសុខដុមរបស់កុមារ។

*ទទួលស្គាល់* សារសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីលើកកំពស់ល័ក្ខខ័ណ្ឌជីវភាពរបស់កុមារនៅគ្រប់ប្រទេស ជាពិសេស ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។

*បានព្រមព្រៀងគ្នាដូចតទៅ :*

## *ផ្នែកទី ១*

### មាត្រា ១

សម្រាប់គោលបំណងនៃអនុសញ្ញានេះ កុមារគឺជាមនុស្សមានអាយុក្រោម ១៨ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ នីតិភាពត្រូវបានកំណត់ទាបជាងនេះ ។

### មាត្រា ២

១. រដ្ឋភាគី ត្រូវគោរព និងធានាសិទ្ធិដូចចែងក្នុងអនុសញ្ញានេះដល់កុមារដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយគ្មានការរើសអើងណាមួយ ដោយឥតគិតពីពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ដើមកំណើតជនជាតិ ឬសង្គម ទ្រព្យសម្បត្តិ អសមត្ថភាពកំណើត ឬស្ថានភាពផ្សេងទៀតរបស់កុមារ របស់ឪពុក-ម្តាយកុមារ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ ។

២. រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងឡាយ ដើម្បីធានាឱ្យកុមារបានទទួលនូវការការពារប្រឆាំងនឹងរាល់ទម្រង់នៃការរើសអើង ឬទណ្ឌកម្មដែលផ្អែកលើមូលដ្ឋានស្ថានភាព សកម្មភាព ការបញ្ចេញមតិ ឬជំនឿរបស់ឪពុក-ម្តាយរបស់អ្នកអាណាព្យាបាលស្របច្បាប់ ឬសមាជិកគ្រួសាររបស់កុមារ។

## មាត្រា ៣

១. នៅក្នុងវិធានការទាំងអស់ដែលពាក់ព័ន្ធនឹងកុមារ ទោះធ្វើឡើងដោយស្ថាប័នឯកជនឬសាធារណៈ ទទួលភារៈខាងសុខុមាលភាពសង្គមឬដោយតុលាការ ឬអាជ្ញាធររដ្ឋបាល ឬអង្គការនីតិបញ្ញត្តិក៏ដោយ ឧត្តមប្រយោជន៍របស់កុមារ ត្រូវតែយកចិត្តទុកដាក់ជាចម្បង ។

២. រដ្ឋភាគីសន្យាធានាដល់កុមារនូវការការពារ និងការថែទាំចាំបាច់ដើម្បីសុខុមាលភាពរបស់កុមារ ដោយយកមកគិតនូវ សិទ្ធិ និងករណីយកិច្ចរបស់ឪពុក-ម្ដាយ អ្នកអាណាព្យាបាល ឬបុគ្គលផ្សេងទៀតដែលទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះកុមារ និងដើម្បីសម្រេចទិសដៅនេះ រដ្ឋភាគីត្រូវចាត់វិធានការខាងនីតិបញ្ញត្តិ និងរដ្ឋបាលដែលសមស្របទាំងអស់ ។

៣. រដ្ឋភាគីត្រូវធានាថា ស្ថាប័ន សេវាកម្ម និងគ្រឹះស្ថានដែលមានបន្ទុកថែទាំ ឬការពារកុមារ ត្រូវធ្វើតាមបទដ្ឋានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចជាពិសេសនៅក្នុងវិស័យនៃសុវត្ថិភាព សុខភាព អំពីចំនួន និងភាពសមស្របនៃបុគ្គលិក ព្រមទាំងសមត្ថកិច្ចគ្រប់គ្រង ។

## មាត្រា ៤

រដ្ឋភាគីសន្យាចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាលនិងវិធានការផ្សេងទៀត ដើម្បីអនុវត្តសិទ្ធិទាំងឡាយដែលទទួលស្គាល់ក្នុងអនុសញ្ញានេះ។ ចំពោះសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រដ្ឋភាគី ត្រូវចាត់វិធានការក្នុងកម្រិតអតិបរមានៃធនធានដែលខ្លួនមាន និងបើចាំបាច់ ក្នុងក្របខ័ណ្ឌនៃសហប្រតិបត្តិការអន្តរជាតិ ។

### មាត្រា ៥

រដ្ឋភាគី ត្រូវគោរពតួនាទី សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្តាយ ឬបើសមស្រប ត្រូវគោរពតួនាទី សិទ្ធិ និងករណីយកិច្ចរបស់សមាជិកគ្រួសារជាសាខាញាតិឬសហគមន៍ អាស្រ័យតាមទំនៀមទម្លាប់នៅមូលដ្ឋាន អ្នកអាណាព្យាបាលស្របច្បាប់ ឬជនផ្សេងទៀតដែលមាននាទីតាមផ្លូវច្បាប់លើកុមារ ក្នុងការតម្រង់ទិស និងការណែនាំសមស្របតាមសមត្ថភាពរបស់កុមារ ដើម្បីឱ្យកុមារប្រើប្រាស់សិទ្ធិទាំងឡាយដែលទទួលស្គាល់ក្នុងអនុសញ្ញានេះ ។

### មាត្រា ៦

១. រដ្ឋភាគីទទួលស្គាល់ថា កុមារគ្រប់រូប មានសិទ្ធិមានជីវិតជាប់ពីកំណើត។

២. រដ្ឋភាគី ត្រូវធានាក្នុងកម្រិតអតិបរមា តាមដែលអាចធ្វើទៅបាន ចំពោះការរស់រាន និងការលូតលាស់របស់កុមារ ។

### មាត្រា ៧

១. កុមារត្រូវបានចុះក្នុងសៀវភៅអត្រានុកូលដ្ឋានភ្លាម បន្ទាប់ពីពេលកើត និងត្រូវមានសិទ្ធិមានឈ្មោះមួយ ពីពេលកើតមក មានសិទ្ធិទទួលបានសញ្ជាតិមួយ និងតាមដែលអាចធ្វើទៅបាន កុមារត្រូវមានសិទ្ធិស្គាល់ឪពុក-ម្តាយ និងទទួលការថែទាំពីឪពុក-ម្តាយ ។

២. រដ្ឋភាគីត្រូវធានាការអនុវត្តសិទ្ធិទាំងនេះ ស្របតាមច្បាប់ជាតិ និងកាតព្វកិច្ចក្រោមលិខិតុបករណ៍អន្តរជាតិក្នុងវិស័យនេះ ពិសេសក្នុងករណីដែលកុមារនឹងក្លាយជាជនឥតស្រុកទេស បើគ្មានការអនុវត្តនោះទេ ។

## មាត្រា ៨

១. រដ្ឋភាគីសន្យាគោរពសិទ្ធិរក្សាអត្តសញ្ញាណរបស់កុមារ រួមមានសញ្ជាតិ ឈ្មោះ និងទំនាក់ទំនងគ្រួសារផង ដូចបានទទួលស្គាល់ក្នុងច្បាប់ ដោយគ្មានការជ្រៀតជ្រែកដោយខុសច្បាប់ឡើយ ។

២. បើកុមារម្នាក់ត្រូវរងការដកហូតដោយខុសច្បាប់ នូវធាតុមួយចំនួន ឬទាំងអស់នៃអត្តសញ្ញាណរបស់ខ្លួននោះ រដ្ឋភាគី ត្រូវផ្តល់ជំនួយ និងការការពារសមស្រប ដើម្បីស្តារអត្តសញ្ញាណរបស់កុមារឡើងវិញឱ្យបានឆាប់រហ័ស ។

## មាត្រា ៩

១. រដ្ឋភាគីត្រូវធានាថា កុមារមិនត្រូវបានបំបែកចេញពីឪពុក-ម្តាយ ផ្ទុយពីឆន្ទៈរបស់កុមារឡើយ លើកលែងតែអាជ្ញាធរមានសមត្ថកិច្ច ដែលស្ថិតក្រោមការពិនិត្យរបស់តុលាការសម្រេចស្របតាមច្បាប់ និងនីតិវិធី ថាការបំបែកនេះគឺចាំបាច់សម្រាប់ឧត្តមប្រយោជន៍របស់កុមារ។ សេចក្តីសម្រេចនេះអាចចាំបាច់តែក្នុងករណីពិសេស មានជាអាទិ៍ ឪពុក-ម្តាយធ្វើបាប ឬទុកចោលមិនយកចិត្តទុកដាក់ ឬឪពុក-ម្តាយមិនរស់នៅជាមួយគ្នា ហើយសេចក្តីសម្រេចនេះ ត្រូវធ្វើដោយគិតពីកន្លែងស្នាក់នៅរបស់កុមារ ។

២. នៅគ្រប់នីតិវិធីស្របតាមកថាខណ្ឌ១ នៃមាត្រានេះ ភាគីពាក់ព័ន្ធទាំងអស់ ត្រូវបានផ្តល់ឱកាសឱ្យចូលរួមក្នុងនីតិវិធីទាំងនោះ និងឱ្យបង្ហាញពីទស្សនៈរបស់ខ្លួន។

៣. រដ្ឋភាគី ត្រូវគោរពសិទ្ធិរបស់កុមារដែលត្រូវបំបែកពីឪពុក ឬម្តាយ ឬឪពុក-ម្តាយទាំងពីរ ក្នុងការរក្សាជាទៀងទាត់ នូវទំនាក់ទំនងផ្ទាល់ខ្លួន និងការទាក់ទងដោយផ្ទាល់ជាមួយឪពុក-ម្តាយ លើកលែងតែប្រការនេះផ្ទុយនឹងឧត្តមប្រយោជន៍របស់កុមារ ។

៤. បើការរស់នៅបែកគ្នាបណ្តាលមកពីវិធានការណាមួយផ្តើមដោយរដ្ឋភាគី មានជាអាទិ៍ ការឃាត់ឬការឃុំខ្លួន ការដាក់ពន្ធនាគារ ការនិរទេស ការបំបរបង់ ឬមរណភាព (រួមទាំងមរណភាពបណ្តាលមកពីបុព្វហេតុណាមួយក្នុងខណៈពេលដែលបុគ្គលនោះត្រូវបានឃាត់ ឬឃុំខ្លួនដោយរដ្ឋ) ឪពុកឬ ម្តាយ ឬឪពុក-ម្តាយទាំងពីរ ឬកុមារ នោះរដ្ឋភាគី ដោយយោងតាមការស្នើសុំ ត្រូវជូនដំណឹងទៅឪពុក-ម្តាយ ឬកុមារ ឬបើសមស្រប ត្រូវជូនដំណឹងទៅសមាជិកគ្រួសារណាម្នាក់ផ្សេងទៀត នូវព័ត៌មានសំខាន់អំពីទីកន្លែងនៃសមាជិកគ្រួសារណាម្នាក់ ឬច្រើននាក់ដែលអវត្តមាន លើកលែងតែការជូនដំណឹងនេះ ប៉ះពាល់ដល់ផាសុខភាពរបស់កុមារ។ ម្យ៉ាងទៀត រដ្ឋភាគីត្រូវធានាថា ការដាក់សេចក្តីស្នើសុំមួយបែបនេះ នឹងមិននាំឱ្យមានផលជាអវិភូតសម្រាប់បុគ្គលពាក់ព័ន្ធឡើយ ។

## មាត្រា ១០

១. ស្របតាមកាតព្វកិច្ចរបស់រដ្ឋភាគី ក្រោមមាត្រា៩ កថាខណ្ឌ១ គ្រប់សេចក្តីស្នើសុំរបស់កុមារ ឬឪពុក ឬម្តាយរបស់កុមារ ដើម្បីចូល ឬចាកចេញពីរដ្ឋភាគី ក្នុងគោលបំណងជួបជុំគ្រួសារ ត្រូវតែដោះស្រាយក្នុងស្មារតីវិជ្ជមាន មនុស្សធម៌ និងឱ្យបានឆាប់រហ័ស ។ ក្រៅពីនេះ រដ្ឋភាគីត្រូវធានាថា ការដាក់សេចក្តីស្នើសុំនេះនឹងមិនបង្កឱ្យមានផលអវិភូតដល់អ្នកសុំ និងដល់សមាជិកគ្រួសាររបស់អ្នកសុំឡើយ ។

២. កុមារដែលមានឪពុក-ម្តាយរស់នៅក្នុងរដ្ឋផ្សេង មានសិទ្ធិរក្សាជាទៀងទាត់នូវទំនាក់ទំនងផ្ទាល់ និងការទាក់ទងដោយផ្ទាល់ ជាមួយឪពុក-ម្តាយទាំងពីរ លើកលែងតែក្នុងកាលៈទេសៈពិសេស។ ក្នុងទិសដៅនេះ និងស្របតាមកាតព្វកិច្ចរបស់រដ្ឋភាគី ក្រោមមាត្រា៩ កថាខណ្ឌ១ រដ្ឋភាគីត្រូវគោរពសិទ្ធិ

របស់កុមារ និងសិទ្ធិឪពុក-ម្តាយរបស់កុមារក្នុងការចាកចេញពីប្រទេស រួមមានប្រទេសរបស់ខ្លួនផង និងវិលចូលមកក្នុងប្រទេសរបស់ខ្លួនវិញ។ សិទ្ធិចាកចេញពីប្រទេសណាមួយ អាចស្ថិតក្រោមការរិតត្បិតបាន លុះត្រាតែការរិតត្បិតនោះ បញ្ញត្តិដោយច្បាប់ និងចាំបាច់ដើម្បីការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ ឬសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ហើយស្របនឹងសិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយអនុសញ្ញានេះ។

## មាត្រា ១១

១. រដ្ឋភាគី ត្រូវចាត់វិធានការប្រយុទ្ធប្រឆាំងនឹងការផ្ទេរកុមារចេញក្រៅប្រទេស ដោយខុសច្បាប់ និងការមិនប្រគល់កុមារពីក្រៅប្រទេសមកវិញ ។

២. ក្នុងទិសដៅនេះ រដ្ឋភាគី ត្រូវសម្រួលដល់ការចុះកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ឬចូលជាសមាជិកក្នុងកិច្ចព្រមព្រៀងដែលមានស្រាប់ ។

## មាត្រា ១២

១. រដ្ឋភាគីត្រូវធានាអះអាងដល់កុមារដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួន នូវសិទ្ធិបញ្ចេញទស្សនៈទាំងនោះដោយសេរី លើគ្រប់បញ្ហាពាក់ព័ន្ធនឹងកុមារ។ ទស្សនៈទាំងនេះរបស់កុមារ ត្រូវបានយកទៅពិចារណាថ្លឹងថ្លែងដោយគិតទៅតាមវ័យ និងភាពចាស់ទុំរបស់កុមារ ។

២. ក្នុងទិសដៅនេះ កុមារត្រូវបានផ្តល់ជាពិសេស នូវឱកាសត្រូវបានគេស្តាប់នៅក្នុងនីតិវិធីតុលាការ និងរដ្ឋបាលដែលពាក់ព័ន្ធនឹងកុមារ ទោះដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង ឬស្ថាប័នសមស្របណាមួយ ស្របតាមបទប្បញ្ញត្តិនីតិវិធីនៃច្បាប់ជាតិ ។

## មាត្រា ១៣

១. កុមារមានសិទ្ធិសម្តែងមតិដោយសេរី។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាព ស្រាវជ្រាវ ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតគ្រប់ប្រភេទ ដោយគ្មានគិតពីព្រំដែន ទោះជាតាមទម្រង់ផ្ទាល់មាត់ សរសេរ ឬបោះពុម្ព ទម្រង់សិល្បៈ ឬតាមគ្រប់គ្រឿងផ្សព្វផ្សាយព័ត៌មានផ្សេងទៀត តាមការជ្រើសរើសរបស់កុមារ។

២. ការប្រើប្រាស់សិទ្ធិនេះ អាចស្ថិតក្រោមការរិតត្បិតខ្លះបាន លុះត្រាតែការរិតត្បិតទាំងនេះ ត្រូវបានអនុញ្ញាតដោយច្បាប់ និងមានលក្ខណៈចាំបាច់ដូចខាងក្រោម:

(ក) ដើម្បីគោរពសិទ្ធិនិងកិត្តិនាមរបស់អ្នកដទៃ ឬ

(ខ) ដើម្បីការពារសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់ សុខភាព ឬសីលធម៌សាធារណៈ ។

## មាត្រា ១៤

១. រដ្ឋភាគី ត្រូវគោរពសិទ្ធិកុមារក្នុងការមានសេរីភាពគិតគូរ សេរីភាពខាងសតិសម្បជញ្ញៈ និងសេរីភាពខាងសាសនា ។

២. រដ្ឋភាគីត្រូវគោរពសិទ្ធិ និងករណីយកិច្ចរបស់ឪពុក-ម្តាយ និងបើសមស្រប អ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ ក្នុងការនាំផ្លូវកុមារឱ្យប្រើប្រាស់សិទ្ធិកុមារ ស្របតាមសមត្ថភាពវិវត្តទៅមុខរបស់កុមារ។

៣. សេរីភាពសម្តែងសាសនា ឬជំនឿរបស់កុមារ អាចស្ថិតក្រោមការរិតត្បិតបាន ដរាបណាមានបញ្ញត្តិដោយច្បាប់ និងចាំបាច់ដើម្បីការពារសុវត្ថិភាព សណ្តាប់ធ្នាប់ សុខភាព និងសីលធម៌សាធារណៈ ឬសិទ្ធិ និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ ។

## មាត្រា ១៥

១. រដ្ឋភាគី ទទួលស្គាល់សិទ្ធិកុមារមានសេរីភាពខាងសមាគម និងមានសេរីភាពប្រជុំដោយសន្តិវិធី ។

២. ការប្រើប្រាស់សិទ្ធិទាំងនេះ អាចស្ថិតក្រោមការរិតត្បិតបាន លុះត្រាតែមានបញ្ញត្តិដោយច្បាប់ និងចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីអត្ថប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ ឬសណ្តាប់ធ្នាប់សាធារណៈ ឬដើម្បីការពារសុខភាព ឬសីលធម៌សាធារណៈ ឬដើម្បីការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ។

## មាត្រា ១៦

១. គ្មានកុមារណាម្នាក់ត្រូវស្ថិតក្រោមការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន ឬការឆ្លើយឆ្លងរបស់កុមារ និងគ្មានកុមារណាម្នាក់ ត្រូវស្ថិតក្រោមការបំពារបំពានដោយខុសច្បាប់លើកិត្តិយស និងកិត្តិនាមរបស់ខ្លួនឡើយ ។

២. កុមារមានសិទ្ធិទទួលបានការការពារដោយច្បាប់ ប្រឆាំងនឹងការជ្រៀតជ្រែក ឬការបំពារបំពានទាំងនេះ ។

## មាត្រា ១៧

រដ្ឋភាគីទទួលស្គាល់សារសំខាន់នៃមុខងារផ្សព្វផ្សាយតាមប្រព័ន្ធឃោសនា និងត្រូវធានាឱ្យកុមារមានសិទ្ធិទទួលបានព័ត៌មាន និងឯកសារឬសម្ភារៈពីប្រភពផ្សេងៗរបស់ជាតិ និងអន្តរជាតិ ជាពិសេស ព័ត៌មាន និងទិន្នន័យដែលសំដៅលើកស្ទួយសុខុមាលភាព ខាងសង្គម ស្មារតី និងសីលធម៌របស់កុមារ ព្រមទាំងសុខភាពផ្នែករាងកាយនិងសតិបញ្ញារបស់កុមារ។ ក្នុងទិសដៅនេះរដ្ឋភាគីត្រូវៈ

(ក) ជំរុញប្រព័ន្ធឃោសនា ឱ្យផ្សព្វផ្សាយព័ត៌មាន និងឯកសារ ឬសម្ភារៈ បង្ហាញពីអត្ថប្រយោជន៍ខាងសង្គម និងវប្បធម៌ដល់កុមារ និងស្របតាមស្មារតីនៃមាត្រា២៩ ។

(ខ) ជំរុញសហប្រតិបត្តិការអន្តរជាតិ ដើម្បីផលិត ផ្លាស់ប្តូរ និងផ្សាយព័ត៌មាន និងឯកសារឬសម្ភារៈដែលចេញមកពីប្រភពប្លែកៗគ្នាខាងវប្បធម៌ជាតិ និងអន្តរជាតិ។

(គ) ជំរុញការផលិត និងការផ្សព្វផ្សាយសៀវភៅសម្រាប់កុមារ ។

(ឃ) ជំរុញប្រព័ន្ធឃោសនា ឱ្យគិតគូរជាពិសេសដល់សេចក្តីត្រូវការផ្នែកភាសារបស់កុមារ ដែលជាសមាជិកក្រុមជនជាតិភាគតិច ឬជាសមាជិកជនអន្តោប្រាម ។

(ង) ជំរុញការកសាងគោលការណ៍ដឹកនាំសមស្រប សំដៅការពារកុមារឱ្យផុតពីព័ត៌មាន និងឯកសារ ឬសម្ភារៈដែលបំផ្លាញសុខុមាលភាពកុមារ ដោយយោងទៅលើបទប្បញ្ញត្តិនៃមាត្រា១៣ និងមាត្រា១៨ ។

## មាត្រា ១៨

១. រដ្ឋភាគីត្រូវប្រឹងប្រែងឱ្យអស់ពីលទ្ធភាព ដើម្បីធានាការទទួលស្គាល់គោលការណ៍ដែលថា ឪពុក-ម្តាយទាំងពីរមានការទទួលខុសត្រូវរួមក្នុងការចិញ្ចឹមបីបាច់ និងធ្វើឱ្យកុមារមានការអភិវឌ្ឍន៍។ ការទទួលខុសត្រូវបឋមក្នុងការចិញ្ចឹមបីបាច់កុមារ និងធ្វើឱ្យកុមារមានការអភិវឌ្ឍន៍ ត្រូវស្ថិតនៅលើឪពុក-ម្តាយ ឬបើពុំនោះទេ អ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ។ ពួកគេនេះ ត្រូវគិតមុនបង្អស់ដល់ឧត្តមប្រយោជន៍របស់កុមារ ។

២. ដើម្បីធានា និងលើកស្ទួយសិទ្ធិដូចចែងក្នុងអនុសញ្ញានេះ រដ្ឋភាគីត្រូវផ្តល់ជំនួយសមស្រួបដល់ឪពុក-ម្តាយ និងអ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ ដើម្បីបំពេញតួនាទីចិញ្ចឹមអប់រំកុមារ និងធានាដល់ការបង្កើតឱ្យមានស្ថាប័ន គ្រឹះស្ថាន និងសេវាកម្មទទួលបន្ទុកថែទាំកុមារ ។

៣. រដ្ឋភាគីត្រូវចាត់វិធានការសមស្របទាំងអស់ ធានាដល់កុមារដែលមានឪពុក-ម្តាយជាអ្នកធ្វើការ នូវសិទ្ធិទទួលអត្ថប្រយោជន៍ពីសេវាកម្ម និងគ្រឹះស្ថានគាំពារកុមារ ដែលកុមារមានលក្ខណៈសម្បត្តិអាចទទួលបាន ។

## មាត្រា ១៩

១. រដ្ឋភាគីត្រូវចាត់វិធានការសមស្របខាងនីតិបញ្ញត្តិ រដ្ឋបាល សង្គមកិច្ច និងខាងអប់រំ ដើម្បីការពារកុមារពីគ្រប់ទម្រង់នៃអំពើហិង្សា ការធ្វើឱ្យរបួស ឬការរំលោភបំពានលើរាងកាយ ឬលើផ្លូវចិត្ត ការទុកចោលមិនយកចិត្តទុកដាក់ ឬការមិនអើពើ ការធ្វើបាប ឬការកេងប្រវ័ញ្ច រួមទាំងការរំលោភបំពានផ្លូវភេទ ក្នុងកំឡុងពេលដែលកុមារស្ថិតនៅក្រោមការចិញ្ចឹមបីបាច់របស់ឪពុក-ម្តាយទាំងពីរ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់ ឬបុគ្គលផ្សេងទៀតដែលមានភារៈថែទាំកុមារ ។

២. វិធានការការពារទាំងនេះ បើសមស្រប គួរបញ្ចូលនីតិវិធីដែលមានប្រសិទ្ធភាព ដើម្បីស្ថាបនាកម្មវិធីសង្គម ដែលផ្តល់ការគាំទ្រចាំបាច់ដល់កុមារ និងអ្នកដែលមានភារៈថែទាំកុមារ និងដើម្បីបង្ការតាមទម្រង់ផ្សេងៗ និងដើម្បីកំណត់អត្តសញ្ញាណ រាយការណ៍ បញ្ជូន ស៊ើបអង្កេត ព្យាបាលនិងតាមដានលើរាល់ករណីនៃការធ្វើបាបកុមារ ដូចលើកឡើងខាងលើ និងបើសមស្រប ដើម្បីកិច្ចអន្តរាគមន៍ពីតុលាការ។

## មាត្រា ២០

១. កុមារ ដែលត្រូវបានដកចេញជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ពីមជ្ឈដ្ឋានគ្រួសាររបស់ខ្លួន ឬដែលឧត្តមប្រយោជន៍របស់កុមារ មិនអាចបណ្តោយឱ្យរស់នៅក្នុងមជ្ឈដ្ឋាននេះបាន មានសិទ្ធិទទួលការការពារ និងជំនួយឧបត្ថម្ភពិសេសពីរដ្ឋ។

២. រដ្ឋភាគី ត្រូវធានាថែទាំកុមារខាងលើនេះ តាមការថែទាំជំនួសស្របតាមច្បាប់ជាតិរបស់ខ្លួន។

៣. ការថែទាំនេះ អាចរាប់បញ្ចូលជាអាទិ៍ ការទុកដាក់ជាមួយឪពុក-ម្តាយធម៌ កាហ្វាឡានៃច្បាប់អ៊ីស្លាម សុំកូន ឬបើសិនជាចាំបាច់ ការដាក់កុមារក្នុងស្ថាប័នសមស្រប ដើម្បីថែទាំកុមារ ។ នៅក្នុងការជ្រើសរើសដំណោះស្រាយនេះ ត្រូវយកចិត្តទុកដាក់លើអត្ថប្រយោជន៍នៃការបន្តថែទាំកុមារ ដូចពេលកន្លងមក ហើយត្រូវយកចិត្តទុកដាក់លើប្រភពជាតិសាសន៍ សាសនា វប្បធម៌ និងភាសារបស់កុមារ។

## មាត្រា ២១

១. រដ្ឋភាគីដែលទទួលស្គាល់ និង/ឬអនុញ្ញាតឱ្យមានប្រព័ន្ធសុំកូន ត្រូវធានាថា ឧត្តមប្រយោជន៍របស់កុមារត្រូវស្ថិតក្នុងការពិចារណាខ្ពស់បំផុត ក្នុងវិស័យនេះ ហើយរដ្ឋភាគីត្រូវ :

(ក) ធានាថា សុំកូនអនុញ្ញាតបានតែដោយអាជ្ញាធរមានសមត្ថកិច្ចជាអ្នកសម្រេច ស្របតាមច្បាប់ និងនីតិវិធីជាធរមាន និងផ្អែកលើមូលដ្ឋានព័ត៌មានពាក់ព័ន្ធ និងគួរជឿទុកចិត្តទាក់ទងនឹងករណីនេះ និងធានាថា សុំកូនអាចអនុញ្ញាតឱ្យធ្វើដោយគិតពីស្ថានភាពកុមារទាក់ទងនឹងឪពុក-ម្តាយ ញាតិសន្តាន ឬ

អ្នកអាណាព្យាបាលស្របច្បាប់ និងបើចាំបាច់ ត្រូវធានាថា ជនពាក់ព័ន្ធបានដឹង និងបានផ្ដល់ការយល់ព្រម បន្ទាប់ពីបានទទួលដំណឹងពីផលប៉ះពាល់នានាចំពោះស្មុំកូន ដោយផ្អែកលើការផ្ដល់ការពិគ្រោះយោបល់ តាមការចាំបាច់ ។

(ខ) ទទួលស្គាល់ថា ស្មុំកូនអន្ដរប្រទេស អាចចាត់ទុកជាមធ្យោបាយជំនួសមួយនៃការថែទាំកុមារបាន បើសិនជានៅក្នុងប្រទេសដើមកំណើតរបស់ខ្លួន កុមារ មិនអាចរស់នៅតាមគ្រួសារធម៌ ឬក្នុងគ្រួសារចិញ្ចឹម ឬមិនអាចទទួលបាននូវការថែទាំឱ្យសមស្របទេនោះ ។

(គ) ធានាថា កុមារពាក់ព័ន្ធនឹងស្មុំកូនអន្ដរប្រទេស បានទទួលការធានា និងបទដ្ឋានដូចគ្នានឹងការធានានិងបទដ្ឋានដែលមានស្រាប់ក្នុងករណីស្មុំកូនក្នុងប្រទេស។

(ឃ) ចាត់វិធានការសមស្របនានាដើម្បីធានាក្នុងករណីស្មុំកូនអន្ដរប្រទេសថា ការផ្ដល់កូននេះពុំបណ្ដាលឱ្យមានផលចំណេញផ្នែកហិរញ្ញវត្ថុដោយមិនត្រឹមត្រូវដល់រាល់បុគ្គលដែលមានការទាក់ទិនក្នុងរឿងនេះឡើយ ។

(ង) ត្រូវលើកស្ទួយទិសដៅនៃមាត្រានេះតាមការធ្វើកិច្ចសម្រុះសម្រួល ឬចុះកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី តាមករណីនីមួយៗ និងប្រឹងប្រែងក្នុងក្របខ័ណ្ឌនេះ ដើម្បីធានាថា ការទុកដាក់នៅក្រៅប្រទេសនេះ ត្រូវបានអនុវត្តដោយអាជ្ញាធរ ឬអង្គការមានសមត្ថកិច្ច ។

### មាត្រា ២២

១. រដ្ឋភាគីត្រូវចាត់វិធានការសមស្របដើម្បីធានាថា កុមារដែលស្វះស្វែងរកឋានៈជាជនភៀសខ្លួន ឬដែលត្រូវបានចាត់ទុកជាជនភៀសខ្លួន ស្របតាមច្បាប់ និងនីតិវិធីអន្ដរជាតិ ឬជាតិជាធរមាន ទោះដោយម្នាក់ឯងក្ដី ឬរួមដំណើរដោយ

ឪពុក-ម្ដាយ ឬជនផ្សេងទៀតក្ដី ត្រូវទទួលបានការការពារ និងជំនួយមនុស្សធម៌សមស្រប ដើម្បីអាស្រ័យផលពីសិទ្ធិពាក់ព័ន្ធ ដូចមានចែងក្នុងអនុសញ្ញានេះ និងក្នុងលិខិតុបករណ៍អន្ដរជាតិស្ដីពីសិទ្ធិមនុស្ស ឬមនុស្សធម៌ ដែលរដ្ឋទាំងនោះជាភាគី ។

២. ក្នុងទិសដៅនេះ រដ្ឋភាគីត្រូវផ្ដល់កិច្ចសហប្រតិបត្តិការដល់ការប្រឹងប្រែងទាំងអស់ ដែលធ្វើឡើងដោយអង្គការសហប្រជាជាតិ និងអង្គការអន្ដររដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាលដែលមានសមត្ថកិច្ចសហការជាមួយអង្គការសហប្រជាជាតិ ដើម្បីការពារ និងជួយឧបត្ថម្ភកុមារ ដែលស្ថិតនៅក្នុងស្ថានភាពដូចគ្នានេះ និងដើម្បីស្វែងរកឪពុក-ម្ដាយ ឬសមាជិកគ្រួសារផ្សេងទៀតរបស់កុមារភៀសខ្លួន ដើម្បីបានមកនូវព័ត៌មានចាំបាច់សម្រាប់កុមារ បានជួបជុំគ្រួសារខ្លួនឡើងវិញ ។ បើរកមិនឃើញឪពុក-ម្ដាយ ឬសមាជិកណាម្នាក់នៃគ្រួសាររបស់កុមារទេ កុមារត្រូវបានទទួលការការពារ ដូចគ្នានឹងកុមារផ្សេងទៀតដែលបាត់បង់មជ្ឈដ្ឋានគ្រួសាររបស់ខ្លួនជាអចិន្ត្រៃយ៍ ឬជាបណ្ដោះអាសន្ន ដោយហេតុផលណាមួយ ដូចចែងក្នុងអនុសញ្ញានេះ ។

## មាត្រា ២៣

១. រដ្ឋភាគីទទួលស្គាល់ថា កុមារពិការខាងសតិបញ្ញា ឬរាងកាយ ត្រូវមានជីវភាពពេញលេញ និងសមរម្យ ក្នុងល័ក្ខខ័ណ្ឌដែលធានាដល់សេចក្ដីថ្លៃថ្នូររបស់កុមារ លើកស្ទួយសេចក្ដីទុកចិត្តលើខ្លួនឯងរបស់កុមារ និងសម្រួលឱ្យកុមារចូលរួមយ៉ាងសកម្មក្នុងសហគមន៍ ។

២. រដ្ឋភាគីទទួលស្គាល់សិទ្ធិទទួលបានការថែទាំពិសេសរបស់កុមារពិការ និងត្រូវជំរុញ និងធានាផ្ដល់តាមធនធានដែលមានឱ្យដល់កុមារពិការដែលមាន

លក្ខណៈសម្បត្តិសមស្រប និងអ្នកដែលមានភារៈថែទាំកុមារ នូវជំនួយឧបត្ថម្ភ តាមការស្នើសុំ និងសមស្របទៅនឹងស្ថានភាពកុមារ និងស្ថានភាពឪពុក-ម្ដាយកុមារ ឬអ្នកផ្សេងទៀតដែលថែទាំកុមារ ។

៣. ដោយទទួលស្គាល់ នូវសេចក្ដីត្រូវការពិសេស របស់កុមារពិការ ជំនួយឧបត្ថម្ភដែលផ្ដល់ស្របតាមកថាខណ្ឌ២ នៃមាត្រានេះ ត្រូវធ្វើដោយឥតគិតថ្លៃរៀងរាល់លើកដែលអាចធ្វើទៅបាន ដោយយោងទៅលើប្រភពធនធានហិរញ្ញវត្ថុរបស់ឪពុក-ម្ដាយកុមារ ឬអ្នកដែលថែទាំកុមារ។ ជំនួយឧបត្ថម្ភត្រូវគ្រោងដើម្បីធានាថា កុមារពិការមានសិទ្ធិទទួល និងទទួលប្រកបដោយប្រសិទ្ធភាព នូវការអប់រំ ការបណ្ដុះបណ្ដាល សេវាថែទាំសុខភាព សេវាស្ដារនីតិសម្បទា ការរៀបចំចាត់ចែង ដើម្បីរកការងារធ្វើ និងឱកាសលំហែកាយដែលមានអត្ថប្រយោជន៍ឱ្យកុមារ សម្រេចបាននូវសមាហរណកម្មដ៏ពេញលេញបំផុតតាមដែលអាចធ្វើបាន និងសម្រេចបានការអភិវឌ្ឍន៍ជាបុគ្គល រួមមាន ការអភិវឌ្ឍន៍ខាងវប្បធម៌ និងស្មារតីរបស់កុមារផង ។

៤. ក្នុងស្មារតីនៃសហប្រតិបត្តិការអន្តរជាតិ រដ្ឋភាគី ត្រូវជំរុញឱ្យមានការផ្លាស់ប្ដូរព័ត៌មានសមស្រប ស្ដីពីការថែទាំបង្ការសុខភាព និងការព្យាបាលតាមបែបវេជ្ជសាស្ត្រ ចិត្តសាស្ត្រ និងមុខងារនៃសរីរាង្គនៃកុមារពិការនោះ រួមមានការផ្សព្វផ្សាយ និងទទួលព័ត៌មានស្ដីពីវិធីនៃការស្ដារនីតិសម្បទា ការអប់រំ និងសេវាខាងវិជ្ជាជីវៈផង ក្នុងទិសដៅឱ្យរដ្ឋភាគីអាចបង្កើនសមត្ថភាព និងការប៉ិនប្រសប់របស់ខ្លួន និងពង្រីកបទពិសោធន៍របស់ខ្លួនក្នុងវិស័យនេះ។ ក្នុងចំណុចនេះ ត្រូវយកចិត្តទុកដាក់ជាពិសេសលើសេចក្ដីត្រូវការនៃប្រទេសដែលកំពុងអភិវឌ្ឍន៍ ។

## មាត្រា ២៤

១. រដ្ឋភាគី ទទួលស្គាល់សិទ្ធិកុមារ ក្នុងការទទួលបានកម្រិតខ្ពស់បំផុតនៃសុខភាព តាមដែលអាចធ្វើទៅបាន ព្រមទាំងសម្ភារៈរូបវ័ន្តសម្រាប់ការព្យាបាលជំងឺ និងស្តារសុខភាព ។ រដ្ឋភាគីត្រូវប្រឹងប្រែងធានាឱ្យបានថា គ្មានកុមារណាម្នាក់ត្រូវបានដកសិទ្ធិទទួលបានសេវាថែទាំសុខភាពទាំងនេះឡើយ ។

២. រដ្ឋភាគី ត្រូវចាត់ចែងអនុវត្តឱ្យបានពេញលេញនូវសិទ្ធិនេះ និងជាពិសេស ត្រូវចាត់វិធានការសមស្រប ដើម្បី:

(ក) បន្ថយមរណភាពនៃទារក និងកុមារ ។

(ខ) ធានាផ្តល់ដល់កុមារទាំងអស់នូវជំនួយសុខាភិបាល និងការថែទាំសុខភាពចាំបាច់នានា ដោយផ្តោតជាពិសេសលើការអភិវឌ្ឍន៍ការថែទាំសុខភាពបឋម ។

(គ) កំចាត់រោគ និងកង្វះអាហារបំប៉នសុខភាព រួមទាំងក្នុងក្របខ័ណ្ឌថែទាំសុខភាពបឋមផង ជាអាទិ៍ តាមរយៈការប្រើប្រាស់បច្ចេកវិជ្ជាដែលមានស្រាប់ និងតាមរយៈការផ្គត់ផ្គង់អាហារបំប៉នគ្រប់គ្រាន់ និងទឹកទទួលទានស្អាត ដោយគិតពីគ្រោះថ្នាក់ និងភ័យន្តរាយនៃភាពកខ្វក់ផ្នែកបរិស្ថាន ។

(ឃ) ធានាឱ្យមាតាទាំងឡាយទទួលបានការថែទាំសុខភាពសមស្របមុនពេល និងក្រោយពេលសម្រាលកូន ។

(ង) ធានាឱ្យគ្រប់ផ្នែកនៃសង្គម ជាពិសេសឪពុក-ម្តាយនិងកុមារ បានទទួលព័ត៌មាន មានសិទ្ធិទទួលការអប់រំ និងទទួលបានការឧបត្ថម្ភក្នុងការប្រើប្រាស់ចំណេះដឹងមូលដ្ឋានស្តីពីសុខភាព និងអាហារបំប៉នកុមារ ប្រយោជន៍នៃការបំបៅកូនដោយទឹកដោះម្តាយ អនាម័យរាងកាយ និងអនាម័យបរិស្ថាន និងការបង្ការគ្រោះថ្នាក់ ។

(ច) បង្កើតការថែទាំសុខភាព ដោយការបង្ការ ផ្តល់ការណែនាំដល់ឪពុក-ម្តាយ ការអប់រំ និងសេវាស្តីពីផែនការគ្រួសារ ។

៣. រដ្ឋភាគី ត្រូវចាត់គ្រប់វិធានការប្រកបដោយប្រសិទ្ធភាពនិងសមស្រប ដើម្បីលុបបំបាត់រាល់ការអនុវត្តជាប្រពៃណីដែលប៉ះពាល់ដល់សុខភាពកុមារ។

៤. រដ្ឋភាគី រ៉ាប់រងលើកស្ទួយ និងលើកទឹកចិត្តដល់សហប្រតិបត្តិការអន្តរជាតិ ដើម្បីធ្វើឱ្យសម្រេចបានពេញលេញជាលំដាប់នូវសិទ្ធិ ដែលត្រូវបានទទួលស្គាល់ក្នុងមាត្រានេះ ។ ចំពោះបញ្ហានេះ ត្រូវយកចិត្តទុកដាក់ជាពិសេសលើសេចក្តីត្រូវការនៃប្រទេសកំពុងអភិវឌ្ឍន៍ ។

## មាត្រា ២៥

រដ្ឋភាគី ទទួលស្គាល់ថា កុមារដែលត្រូវបានទុកដាក់ដោយអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលបំណង ដើម្បីថែទាំ ការពារ ឬព្យាបាលសុខភាពរាងកាយ ឬសតិបញ្ញា មានសិទ្ធិទទួលបានការពិនិត្យមើលជាទៀងទាត់នូវការថែទាំខ្លួន និងគ្រប់ស្ថានភាពផ្សេងទៀតពាក់ព័ន្ធនឹងការទុកដាក់នោះ ។

## មាត្រា ២៦

១. រដ្ឋភាគីត្រូវទទួលស្គាល់សិទ្ធិរបស់កុមារគ្រប់រូប ក្នុងការទទួលអត្ថប្រយោជន៍ពីសន្តិសុខសង្គម រួមមានកិច្ចធានារ៉ាប់រងសង្គមផង និងត្រូវចាត់វិធានការចាំបាច់ ដើម្បីធ្វើឱ្យសម្រេចបាន នូវការប្រើប្រាស់ពេញលេញនូវសិទ្ធិនេះ ស្របតាមច្បាប់ជាតិរបស់ខ្លួន ។

២. ផលប្រយោជន៍ទាំងនេះ បើសមស្រប ត្រូវតែផ្តល់ឱ្យដោយគិតតាមធនធាន និងស្ថានភាពរបស់កុមារ និងអ្នកដែលមានភារកិច្ចថែទាំកុមារ ព្រមទាំងការពិចារណាផ្សេងទៀត ពាក់ព័ន្ធនឹងការស្នើសុំផលប្រយោជន៍ ដែលធ្វើឡើងដោយកុមារ ឬក្នុងនាមកុមារ ។

## មាត្រា ២៧

១. រដ្ឋភាគីទទួលស្គាល់សិទ្ធិរបស់កុមារគ្រប់រូបក្នុងការមានកម្រិតជីវភាពគ្រប់គ្រាន់ សម្រាប់ការអភិវឌ្ឍន៍រាងកាយ សតិបញ្ញា ស្មារតី សីលធម៌ និងសង្គមរបស់កុមារ ។

២. ឪពុក-ម្ដាយ ឬអ្នកផ្សេងទៀតដែលទទួលបន្ទុកលើកុមារ គឺជាអ្នកទទួលខុសត្រូវបឋម ក្នុងការធានាឱ្យមានតាមលទ្ធភាព និងសមត្ថភាពហិរញ្ញវត្ថុរបស់ខ្លួន នូវល័ក្ខខ័ណ្ឌនៃការរស់នៅដែលចាំបាច់ សម្រាប់ការរីកលូតលាស់របស់កុមារ ។

៣. រដ្ឋភាគី ដោយយោងតាមស្ថានភាពជាតិ និងក្នុងកម្រិតមធ្យោបាយរបស់ខ្លួន ត្រូវចាត់វិធានការសមស្របនានា ដើម្បីជួយឧបត្ថម្ភដល់ឪពុក-ម្ដាយ និងអ្នកផ្សេងទៀតដែលទទួលបន្ទុកលើកុមារ ដើម្បីអនុវត្តសិទ្ធិនេះ ហើយក្នុងករណីចាំបាច់ ត្រូវឧបត្ថម្ភសម្ភារៈ និងផ្ដល់កម្មវិធីគាំទ្រនានា ជាពិសេសទាក់ទងនឹងចំណីអាហារ សំលៀកបំពាក់ និងកន្លែងស្នាក់នៅ ។

៤. រដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីធ្វើឱ្យកុមារទទួលបាននូវអាហារកិច្ចពីឪពុក-ម្ដាយ ឬពីបុគ្គលផ្សេងទៀតដែលទទួលបន្ទុកផ្នែកហិរញ្ញវត្ថុសម្រាប់កុមារ ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស។ ជាពិសេស បើអ្នកទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ សម្រាប់កុមាររស់នៅក្នុងប្រទេសផ្សេងពីប្រទេសរបស់កុមារ រដ្ឋភាគីត្រូវជំរុញឱ្យមានការចូលជាសមាជិកនៃកិច្ចព្រមព្រៀងអន្តរជាតិ ឬការចុះកិច្ចព្រមព្រៀងបែបនេះ ព្រមទាំងការរៀបចំសមស្របផ្សេងៗទៀត ។

## មាត្រា ២៨

១. រដ្ឋភាគី ទទួលស្គាល់សិទ្ធិកុមារ ក្នុងការទទួលបានការអប់រំ ហើយដើម្បីអនុវត្តសិទ្ធិនេះឱ្យកាន់តែប្រសើរឡើងជាលំដាប់ និងផ្អែកលើមូលដ្ឋាននៃឱកាសស្មើភាព ជាពិសេស រដ្ឋភាគីត្រូវ :

(ក) ធ្វើឱ្យការអប់រំកម្រិតបឋមមានលក្ខណៈជាកាតព្វកិច្ច និងឥតបង់ថ្លៃ សម្រាប់គ្រប់គ្នា ។

(ខ) ជំរុញការអភិវឌ្ឍន៍ទម្រង់ផ្សេងៗនៃការអប់រំកម្រិតមធ្យម រួមមានការអប់រំចំណេះទូទៅ និងវិជ្ជាជីវៈផង បើកឱ្យមាន និងទទួលបានដល់កុមារគ្រប់រូប និងចាត់វិធានការសមស្របនានា មានជាអាទិ៍ ការបង្កើតការអប់រំឥតបង់ថ្លៃ និងការផ្តល់ជំនួយហិរញ្ញវត្ថុក្នុងករណីចាំបាច់។

(គ) ធានាតាមគ្រប់មធ្យោបាយសមស្រប ឱ្យមានការអប់រំថ្នាក់ឧត្តមសម្រាប់ជនគ្រប់រូប ដោយយកសមត្ថភាពជាមូលដ្ឋាន ។

(ឃ) បើកឱ្យមាន និងធ្វើឱ្យកុមារទាំងអស់បានទទួលព័ត៌មាន និងការណែនាំស្តីពីការអប់រំ និងវិជ្ជាជីវៈ ។

(ង) ចាត់វិធានការជំរុញឱ្យមានការចូលរៀនទៀងទាត់ និងកាត់បន្ថយអត្រាបោះបង់ចោលការសិក្សា ។

២. រដ្ឋភាគី ត្រូវចាត់វិធានការសមស្រប ដើម្បីធានាថា វិន័យសាលាត្រូវបានអនុវត្តក្នុងបែបផែន ស្របនឹងសេចក្តីថ្លៃថ្នូរជាមនុស្សរបស់កុមារ និងស្របតាមអនុសញ្ញានេះ ។

៣. រដ្ឋភាគី ត្រូវលើកស្ទួយ និងលើកទឹកចិត្តដល់សហប្រតិបត្តិការអន្តរជាតិក្នុងវិស័យអប់រំ ជាពិសេសដើម្បីរួមចំណែកលុបបំបាត់ភាពអវិជ្ជា និងអនក្ខរ

ភាពទូទាំងពិភពលោក និងដើម្បីសម្រួលសិទ្ធិទទួលបាននូវចំណេះដឹងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេស និងវិធីបង្រៀនបែបទំនើប ។ ក្នុងបញ្ហានេះ ត្រូវយកចិត្តទុកដាក់ជាពិសេសលើសេចក្ដីត្រូវការរបស់ប្រទេសដែលកំពុងអភិវឌ្ឍន៍។

មាត្រា ២៩

១. រដ្ឋភាគី យល់ស្របថា ការអប់រំកុមារត្រូវតែឆ្ពោះទៅរកៈ

(ក) ការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈ ទេពកោសល្យ សមត្ថភាពកាយ និងសតិបញ្ញារបស់កុមារ ឱ្យដល់សក្ដានុពលភាពពេញទំហឹងបំផុតរបស់កុមារ។

(ខ) ការបណ្ដុះគំនិតដល់កុមារឱ្យគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាននិងគោលការណ៍ទាំងឡាយដែលមានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ។

(គ) ការបណ្ដុះគំនិតដល់កុមារ ឱ្យចេះគោរពឪពុក-ម្ដាយ អត្តសញ្ញាណវប្បធម៌ ភាសា និងតម្លៃរបស់ខ្លួន ការគោរពតម្លៃជាតិនៃប្រទេសដែលកុមារកំពុងរស់នៅ ការគោរពតម្លៃជាតិ នៃប្រទេសដែលអាចជាដើមកំណើតរបស់កុមារ និងគោរពអារ្យធម៌នានាដែលខុសពីអារ្យធម៌ផ្ទាល់ខ្លួនរបស់កុមារ ។

(ឃ) ការរៀបចំចាត់ចែងឱ្យកុមាររស់នៅ ប្រកបដោយការទទួលខុសត្រូវ ក្នុងសង្គមសេរី ក្នុងស្មារតីយោគយល់គ្នា សន្តិភាព អត់ឱនឱ្យគ្នា សមភាពភេទ និងមិត្តភាពរវាងប្រជាជាតិទាំងអស់ ក្រុមជាតិពន្ធ ជនជាតិ និងសាសនា និងជនអន្ដោប្រាណ ។

(ង) ការបណ្ដុះគំនិតដល់កុមារ ឱ្យគោរពបរិស្ថានធម្មជាតិ ។

២. គ្មានផ្នែកណាមួយនៃមាត្រានេះ ឬមាត្រា២៨ ត្រូវបានយកមកបកស្រាយ ធ្វើឱ្យប៉ះពាល់ដល់សេរីភាពរបស់រូបវ័ន្តបុគ្គល ឬនីតិបុគ្គល ក្នុងការបង្កើត និងដឹកនាំគ្រឹះស្ថានសិក្សាឡើយ ជានិច្ចកាល ត្រូវតែគោរពតាមគោលការណ៍ដែលមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ត្រូវតែបំពេញទៅតាមលក្ខខណ្ឌតំរូវដែលថាការអប់រំដែលផ្តល់ក្នុងគ្រឹះស្ថានទាំងនោះ ស្របតាមបទដ្ឋានអប្បបរមាតាមការកំណត់របស់រដ្ឋ ។

## មាត្រា ៣០

នៅក្នុងរដ្ឋដែលមានជនភាគតិចខាងជាតិពន្ធុ សាសនា ឬភាសា ឬជនអន្តោប្រវេសន៍ ... 

គ្រាម កុមារជាសមាជិកនៃជនភាគតិច ឬជនអន្តោគ្រាមនេះ មិនត្រូវទទួលរងនូវការបដិសេធសិទ្ធិមានជីវភាពវប្បធម៌ សិទ្ធិសំដែង និងប្រតិបត្តិសាសនា ឬប្រើភាសាផ្ទាល់ខ្លួនដោយរួមជាមួយសមាជិកផ្សេងទៀតនៃក្រុមរបស់ខ្លួនឡើយ។

## មាត្រា ៣១

១. រដ្ឋភាគី ទទួលស្គាល់សិទ្ធិរបស់កុមារ ក្នុងការសម្រាក និងលំហែកាយ ចូលរួមក្នុងការលេង និងក្នុងសកម្មភាពកំសាន្តផ្សេងៗ សមស្របតាមអាយុរបស់កុមារ និងចូលរួមដោយសេរីក្នុងជីវភាពវប្បធម៌ និងសិល្បៈ ។

២. រដ្ឋភាគីត្រូវគោរព និងលើកស្ទួយសិទ្ធិរបស់កុមារ ក្នុងការចូលរួមយ៉ាងពេញលេញក្នុងជីវភាពវប្បធម៌ និងសិល្បៈ និងត្រូវជំរុញឱ្យមានការផ្តល់ឱកាសសមស្រប និងស្មើភាពសម្រាប់សកម្មភាពវប្បធម៌ សិល្បៈ លេងកំសាន្ត និងលំហែកាយ ។

## មាត្រា ៣២

១. រដ្ឋភាគី ទទួលស្គាល់សិទ្ធិការពារកុមារ ប្រឆាំងការកេងប្រវ័ញ្ចសេដ្ឋកិច្ច និងការឱ្យធ្វើការងារប្រកបដោយគ្រោះថ្នាក់ ឬដែលអាចប៉ះពាល់ដល់ការសិក្សារបស់កុមារ ឬដែលអាចបំផ្លាញសុខភាព ឬការអភិវឌ្ឍន៍រាងកាយ សតិបញ្ញា ស្មារតី សីលធម៌ ឬសង្គមរបស់កុមារ ។

២. រដ្ឋភាគីត្រូវចាត់វិធានការខាងផ្លូវច្បាប់ រដ្ឋបាល សង្គម និងការអប់រំ ដើម្បីធានាដល់ការអនុវត្តមាត្រានេះ ។ ក្នុងទិសដៅនេះ និងយោងតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងលិខិតុបករណ៍អន្តរជាតិផ្សេងទៀត រដ្ឋភាគី ជាពិសេស:

(ក) ត្រូវកំណត់អាយុអប្បបរមាមួយ ឬអាយុអប្បបរមាច្រើនសម្រាប់ចូលធ្វើការ។

(ខ) ត្រូវចែងបទបញ្ញត្តិសមស្របស្ដីពីម៉ោងពេលនិងល័ក្ខខ័ណ្ឌការងារ។

(គ) ត្រូវកំណត់ទោស ឬទណ្ឌកម្មសមស្របផ្សេងទៀតដើម្បីធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវមាត្រានេះ ។

## មាត្រា ៣៣

រដ្ឋភាគីត្រូវចាត់វិធានការសមស្រប រួមបញ្ចូលទាំងវិធានការខាងផ្លូវច្បាប់ រដ្ឋបាល សង្គម និងការអប់រំ ដើម្បីការពារកុមារឱ្យផុតពីការប្រើប្រាស់ខុសច្បាប់នូវថ្នាំញៀន និងសារជាតិសណ្ដំស្មារតី ដូចមានកំណត់ក្នុងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធ និងដើម្បីទប់ស្កាត់ការប្រើប្រាស់កុមារក្នុងការផលិត និងការជួញដូរខុសច្បាប់នូវសារជាតិទាំងនេះ ។

## មាត្រា ៣៤

រដ្ឋភាគី រ៉ាប់រងការពារកុមារ ឱ្យផុតពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ ។ ក្នុងទិសដៅនេះ រដ្ឋភាគី ជាពិសេស ត្រូវចាត់វិធានការសមស្របនានា ក្នុងក្របខ័ណ្ឌជាតិ ក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ដើម្បីទប់ស្កាត់ :

(ក) ការអូសទាញ ឬការបង្ខិតបង្ខំកុមារ ឱ្យចូលរួមក្នុងសកម្មភាពខាងផ្លូវភេទខុសច្បាប់ ។

(ខ) ការប្រើប្រាស់កុមារក្នុងពេស្យាកម្មកេងប្រវ័ញ្ច ឬប្រព្រឹត្តដោយខុសច្បាប់ខាងផ្លូវភេទផ្សេងទៀត។

(គ) ការប្រើប្រាស់កុមារដោយកេងប្រវ័ញ្ច នៅក្នុងការសម្តែងអាសអាភាស និងផលិតសម្ភារៈ ឬរូបភាពអាសអាភាស។

## មាត្រា ៣៥

រដ្ឋភាគី ត្រូវចាត់វិធានការសមស្របក្នុងក្របខ័ណ្ឌជាតិ ទ្វេភាគី និងពហុភាគី ដើម្បីទប់ស្កាត់ការចាប់ពង្រត់ ការលក់ ឬការជួញដូរកុមារ ទោះក្នុងគោលបំណងអ្វី ឬទម្រង់ណាក៏ដោយ ។

## មាត្រា ៣៦

រដ្ឋភាគីត្រូវការពារកុមារប្រឆាំងនឹងទម្រង់ផ្សេងទៀតទាំងអស់នៃការកេងប្រវ័ញ្ចដែលប៉ះពាល់ដល់គ្រប់ទិដ្ឋភាពណាមួយនៃសុខុមាលភាពរបស់កុមារ ។

## មាត្រា ៣៧

រដ្ឋភាគីត្រូវធានាថា :

(ក) គ្មានកុមារណាម្នាក់ ត្រូវទទួលរងទារុណកម្ម ឬការប្រព្រឹត្តទៅលើខ្លួន ឬការផ្តន្ទាទោស ឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។ ទោសប្រហារជីវិត ឬដាក់គុកអស់មួយជីវិត ដោយគ្មានលទ្ធភាពដោះលែង មិនត្រូវដាក់ចំពោះបទល្មើសដែលប្រព្រឹត្តដោយមនុស្សមានអាយុក្រោម១៨ឆ្នាំឡើយ។

(ខ) គ្មានកុមារណាម្នាក់ ត្រូវបានដកហូតសេរីភាពដោយខុសច្បាប់ ឬតាមអំពើចិត្តឡើយ។ ការចាប់ខ្លួន ការឃាត់ឬការឃុំខ្លួន ឬការដាក់ពន្ធនាគារកុមារ ត្រូវធ្វើស្របតាមច្បាប់ និងត្រូវប្រើសម្រាប់តែវិធានការចុងក្រោយ និងសម្រាប់រយៈពេលខ្លីបំផុត ។

(គ) កុមារណាដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួន ប្រកបដោយមនុស្សធម៌ ដោយការគោរពចំពោះសេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្ស និងគិតដល់សេចក្តីត្រូវការរបស់មនុស្សក្នុងវ័យរបស់ខ្លួន ។ ជាពិសេស រាល់កុមារដែលត្រូវបានដកហូតសេរីភាព ត្រូវដាក់ឱ្យនៅដោយឡែកពីមនុស្សពេញវ័យ លើកលែងតែឧត្តមប្រយោជន៍របស់កុមារ មិនតម្រូវឱ្យធ្វើដូច្នេះ ហើយកុមារទាំងនេះត្រូវមានសិទ្ធិទាក់ទងជាមួយគ្រួសារខ្លួនតាមរយៈការឆ្លើយឆ្លង និងការជួបសួរសុខទុក្ខ លើកលែងតែក្នុងកាលៈទេសៈពិសេសចេញ។

(ឃ) កុមារដែលត្រូវបានដកហូតសេរីភាព មានសិទ្ធិទទួលបានភ្លាមៗនូវជំនួយផ្នែកច្បាប់ និងជំនួយសមស្របផ្សេងៗទៀត និងមានសិទ្ធិជំទាស់ភាពស្របច្បាប់នៃការដកហូតសេរីភាពខ្លួន នៅចំពោះមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង និងមានសិទ្ធិទទួលបានសេចក្តីសម្រេចយ៉ាងឆាប់លើចំណាត់ការបែបនេះ ។

## មាត្រា ៣៨

១. រដ្ឋភាគីរ៉ាប់រង និងធានាឱ្យមានការគោរពវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិដែលអនុវត្តទៅលើរដ្ឋភាគីដែលមានជម្លោះប្រដាប់អាវុធ ហើយពាក់ព័ន្ធនឹងកុមារ។

២. រដ្ឋភាគី ត្រូវចាត់វាល់វិធានការដែលអាចធ្វើទៅបាន ដើម្បីធានាថា មនុស្សដែលមិនទាន់ដល់អាយុ ១៥ឆ្នាំ មិនត្រូវចូលរួមដោយផ្ទាល់ក្នុងអរិភាពឡើយ។

៣. រដ្ឋភាគី ត្រូវជៀសវាងរើសមនុស្សដែលមានអាយុមិនទាន់ដល់១៥ឆ្នាំ ឱ្យចូលបំរើក្នុងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន ។ ក្នុងការរើសទ័ព ក្នុងចំណោមមនុស្សដែលមានអាយុចាប់ពី១៥ឆ្នាំឡើង ប៉ុន្តែមិនទាន់ដល់អាយុ១៨ឆ្នាំ រដ្ឋភាគីត្រូវខំប្រឹងប្រែងជ្រើសរើសមនុស្ស ដែលមានអាយុច្រើនជាងគេបំផុតជាអាទិភាព ។

៤. ស្របទៅតាមកាតព្វកិច្ចរបស់រដ្ឋ ក្រោមច្បាប់មនុស្សធម៌អន្តរជាតិ ដើម្បីការពារជនស៊ីវិលក្នុងជម្លោះប្រដាប់អាវុធ រដ្ឋភាគី ត្រូវចាត់វាល់វិធានការដែលអាចធ្វើទៅបាន ដើម្បីធានាការពារ និងថែទាំកុមារដែលប៉ះពាល់ដោយជម្លោះប្រដាប់អាវុធ ។

## មាត្រា ៣៩

រដ្ឋភាគី ត្រូវចាត់វាល់វិធានការសមស្រប ដើម្បីជំរុញការស្តារកាយសម្បទា និងចិត្តសាស្ត្រឱ្យមានដូចដើមវិញ និងសមាហរណកម្មសង្គមកុមាររងគ្រោះ ពីទម្រង់ណាមួយនៃការទុកចោលមិនយកចិត្តទុកដាក់ ការកេងប្រវ័ញ្ចឬការរំលោភបំពាន ការធ្វើទារុណកម្ម ឬទម្រង់ណាមួយនៃការប្រព្រឹត្តកម្មទៅលើខ្លួន ឬការ

ផ្តន្ទាទោស ឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬដោយសារជម្លោះប្រដាប់អាវុធ។ ការស្តារ និងសមាហរណកម្មទាំងនេះ ត្រូវប្រព្រឹត្តក្នុងបរិយាកាសមួយដែលលើកស្ទួយសុខភាព ការគោរពតម្លៃខ្លួនឯង និងសេចក្តីថ្លៃថ្នូររបស់កុមារ។

### មាត្រា ៤០

១. រដ្ឋភាគីទទួលស្គាល់ថា កុមារដែលជាប់សង្ស័យ ជាប់ចោទ ឬដែលគេស្គាល់ថា បានល្មើសនឹងច្បាប់ព្រហ្មទណ្ឌ មានសិទ្ធិទទួលបាននូវការប្រព្រឹត្តមកលើខ្លួន តាមលក្ខណៈមួយដែលលើកស្ទួយសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់កុមារដែលពង្រឹងកុមារ ឱ្យចេះគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ ដោយគិតពីអាយុរបស់កុមារ ព្រមទាំងពីអត្ថប្រយោជន៍នៃការលើកស្ទួយការធ្វើសមាហរណកម្មកុមារមកក្នុងសង្គមវិញ និងឱ្យកុមារបំពេញតួនាទីស្ថាបនានៅក្នុងសង្គម។

២. ក្នុងទិសដៅនេះ និងដោយគិតទៅនឹងបទប្បញ្ញត្តិនៃលិខិតុបករណ៍អន្តរជាតិដែលពាក់ព័ន្ធ រដ្ឋភាគីត្រូវធានា ជាពិសេសថា :

(ក) គ្មានកុមារណាម្នាក់ ត្រូវជាប់សង្ស័យ ជាប់ចោទ ឬទទួលស្គាល់ថាបានល្មើសនឹងច្បាប់ព្រហ្មទណ្ឌដោយសារអំពើ ឬការខកខានដែលច្បាប់ជាតិ ឬច្បាប់អន្តរជាតិ មិនបានហាមឃាត់នៅពេលអំពើ ឬការខកខាននោះត្រូវបានប្រព្រឹត្ត ។

(ខ) កុមារដែលជាប់សង្ស័យ ឬជាប់ចោទថា បានរំលោភច្បាប់ព្រហ្មទណ្ឌ យ៉ាងហោចណាស់ ត្រូវទទួលបាននូវការធានាដូចតទៅ :

(i) ចាត់ទុកកុមារថាឥតទោស រហូតទាល់តែពិរុទ្ធភាពត្រូវបានបង្ហាញស្របតាមច្បាប់។

(ii) ប្រាប់កុមារភ្លាមៗ និងដោយផ្ទាល់ អំពីបទចោទមកលើខ្លួន ឬបើសមស្រប ប្រាប់តាមរយៈឪពុក-ម្ដាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ និងផ្ដល់ជំនួយផ្នែកច្បាប់ ឬជំនួយសមស្របផ្សេងទៀត សម្រាប់ការរៀបចំ និងដាក់ចេញនូវមធ្យោបាយការពារខ្លួន ។

(iii) ទទួលបានការដោះស្រាយបញ្ហាដោយគ្មានការយឺតយ៉ាវពីសំណាក់អាជ្ញាធរ ឬស្ថាប័នតុលាការដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀងនៅក្នុងការជំនុំជំរះដ៏យុត្តិធម៌មួយ ដែលសមស្របទៅតាមច្បាប់ និងដោយមានជំនួយផ្នែកច្បាប់ ឬជំនួយសមស្របផ្សេងៗទៀត ហើយប្រសិនបើមិនផ្ទុយនឹងឧត្ដមប្រយោជន៍របស់កុមារនោះ ជាពិសេស ដោយយោងទៅលើអាយុ ឬស្ថានភាពរបស់កុមារដោយមានវត្តមានរបស់ឪពុក-ម្ដាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់កុមារផង។

(iv) មិនត្រូវទទួលរងការបង្ខិតបង្ខំឱ្យផ្ដល់សក្ខីកម្ម ឬសារភាពកំហុសឡើយ។ ត្រូវសួរចម្លើយ ឬឱ្យមានការសួរចម្លើយសាក្សីដាក់បន្ទុក និងត្រូវឱ្យមានការចូលរួម និងការសួរចម្លើយសាក្សីដោះបន្ទុកក្នុងនាមកុមារ ក្រោមល័ក្ខខ័ណ្ឌសមភាព ។

(v) បើយល់ឃើញថា បានរំលោភច្បាប់ព្រហ្មទណ្ឌ កុមារអាចសុំឱ្យអាជ្ញាធរ ដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ឬតុលាការថ្នាក់លើពិនិត្យឡើងវិញលើសេចក្ដីសម្រេចនេះ និងលើវិធានការណាមួយដែលដាក់បង្ខំតាមសេចក្ដីសម្រេចនេះដោយស្របតាមច្បាប់។

(vi) ទទួលបានដោយឥតគិតថ្លៃនូវជំនួយពីអ្នកបកប្រែ បើកុមារមិនអាចយល់ ឬនិយាយភាសាដែលត្រូវបានប្រើនោះទេ។

(vii) ត្រូវគោរពយ៉ាងពេញលេញនូវសិទ្ធិនៃជីវិតឯកជនរបស់កុមារ នៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី។

៣. រដ្ឋភាគី ត្រូវខិតខំលើកស្ទួយការបង្កើតច្បាប់ នីតិវិធី អាជ្ញាធរ និងស្ថាប័នសម្រាប់អនុវត្ត ជាពិសេសទៅលើកុមារដែលជាប់សង្ស័យ ជាប់ចោទ ឬទទួលស្គាល់ថា បានរំលោភច្បាប់ព្រហ្មទណ្ឌ និងជាពិសេស :

(ក) ត្រូវកំណត់អាយុអប្បបរមាដែលក្រោមអាយុអប្បបរមានេះ កុមារត្រូវបានសន្មត់ជាមុនថា ពុំមានសមត្ថភាពរំលោភច្បាប់ព្រហ្មទ័ណ្ឌឡើយ។

(ខ) ក្នុងករណីសមស្រប និងចាំបាច់ វិធានការសម្រាប់ដោះស្រាយចំពោះកុមារទាំងនេះ មិនចាំបាច់ឆ្លងកាត់នីតិវិធីតុលាការឡើយ ឱ្យតែធានា និងគោរពបានពេញលេញនូវសិទ្ធិមនុស្ស និងការធានាខាងផ្លូវច្បាប់ ។

៤. ចំណាត់ការមួយចំនួនដូចជា ការថែទាំ របៀបណែនាំ និងដីកាតាមដានការពិគ្រោះយោបល់ ការសាកល្បងឱ្យនៅក្រៅឃុំ ការថែទាំដោយឪពុក-ម្ដាយធម៌ កម្មវិធីអប់រំនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងមធ្យោបាយផ្សេងៗទៀតជំនួសការថែទាំតាមស្ថាប័ន ត្រូវធ្វើឱ្យមាន ដើម្បីធានាថា កុមារទទួលបាននូវចំណាត់ការដែលសមស្រប ចំពោះសុខុមាលភាពរបស់ខ្លួន និងមានសមាមាត្រទៅនឹងស្ថានភាពរបស់កុមារ និងបទល្មើស។

## មាត្រា ៤១

គ្មានបទប្បញ្ញត្តិណាមួយនៃអនុសញ្ញានេះ ធ្វើឱ្យប៉ះពាល់ដល់បទប្បញ្ញត្តិណាមួយដែលមានអំណោយផលល្អជាង ក្នុងការធ្វើឱ្យសម្រេចដល់សិទ្ធិទាំងឡាយរបស់កុមារ ហើយដែលអាចមានចែងក្នុង :

(ក) ច្បាប់របស់រដ្ឋភាគី ឬ

(ខ) ច្បាប់អន្តរជាតិដែលចូលធរមានសម្រាប់រដ្ឋនោះ។

## ផ្នែកទី ២

### មាត្រា ៤២

រដ្ឋភាគី រ៉ាប់រងផ្សព្វផ្សាយយ៉ាងទូលំទូលាយ នូវគោលការណ៍ និងបទប្បញ្ញត្តិនៃអនុសញ្ញានេះ តាមមធ្យោបាយសមស្រប និងជីសកម្ម ដល់មនុស្សពេញវ័យ ក៏ដូចជាកុមារផងដែរ។

### មាត្រា ៤៣

១. ក្នុងគោលបំណងពិនិត្យការវិវត្តទៅមុខនៃការសម្រេចបាននូវការបំពេញកាតព្វកិច្ចក្នុងអនុសញ្ញានេះ ដែលរ៉ាប់រងដោយរដ្ឋភាគី គណៈកម្មាធិការស្តីពីសិទ្ធិកុមារមួយ ត្រូវបានបង្កើតឡើង។ គណៈកម្មាធិការមានមុខងារកំណត់ដូចតទៅនេះ។

២. គណៈកម្មាធិការត្រូវមានអ្នកជំនាញការចំនួន១០រូបដែលមានសីលធម៌ខ្ពស់ និងមានសមត្ថកិច្ចដែលគេទទួលស្គាល់ក្នុងវិស័យដូចចែងក្នុងអនុសញ្ញានេះ។ សមាជិកនៃគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោតដោយរដ្ឋភាគី ពីក្នុងចំណោមជនជាតិរបស់ខ្លួន និងត្រូវធ្វើការក្នុងសមត្ថកិច្ចជាបុគ្គល ដោយធ្វើការពិចារណាបែងចែកទៅតាមភូមិសាស្ត្រ ដោយសមធម៌ ព្រមទាំងទៅតាមប្រព័ន្ធច្បាប់ធំៗ។

៣. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោតជាសម្ងាត់ពីបញ្ជីឈ្មោះបេក្ខជន ដែលជ្រើសតាំងដោយរដ្ឋភាគី។ រដ្ឋភាគីនីមួយៗ អាចជ្រើសតាំងបេក្ខជន១រូប ពីក្នុងចំណោមជនជាតិរបស់ខ្លួន។

៤. ការបោះឆ្នោតលើកដំបូង ត្រូវរៀបចំឡើងក្នុងរយៈពេលមិនឱ្យលើសពី ៦ខែ បន្ទាប់ពីកាលបរិច្ឆេទដែលអនុសញ្ញានេះ ចូលជាធរមាន និងបន្ទាប់មក ការបោះឆ្នោតត្រូវរៀបចំឡើងរៀងរាល់ពីរឆ្នាំម្តង។ យ៉ាងតិច៤ខែ មុនដល់កាល បរិច្ឆេទកំណត់នៃការបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចេញលិខិតអញ្ជើញ ឱ្យរដ្ឋភាគីដាក់បញ្ជីឈ្មោះបេក្ខជនរបស់ខ្លួន ក្នុងរយៈ ពេល២ខែ។ បន្ទាប់មកអគ្គលេខាធិការ ត្រូវរៀបចំបញ្ជីឈ្មោះបេក្ខជនទាំងអស់ តាមលំដាប់អក្សរក្រម ដោយបញ្ជាក់ឈ្មោះរដ្ឋភាគី ដែលបានជ្រើសតាំងបេក្ខ ជនទាំងនោះ ហើយត្រូវបញ្ជូនបញ្ជីឈ្មោះនេះទៅរដ្ឋភាគីនៃអនុសញ្ញានេះ។

៥. ការបោះឆ្នោត ត្រូវរៀបចំឡើងក្នុងសម័យប្រជុំនៃរដ្ឋភាគី នៅទីស្នាក់ ការអង្គការសហប្រជាជាតិ តាមការកោះអញ្ជើញដោយអគ្គលេខាធិការ។ កូរ៉ុម សម្រាប់កិច្ចប្រជុំ គឺពីរភាគបីនៃរដ្ឋភាគីនៃអនុសញ្ញានេះ បេក្ខជនដែលជាប់ជា សមាជិកគណៈកម្មាធិការ ត្រូវតែជាបេក្ខជនទទួលបានសម្លេងច្រើនបំផុត និង សម្លេងភាគច្រើនដាច់ខាតពីតំណាងរបស់រដ្ឋភាគីដែលមានវត្តមាន និងបានបោះ ឆ្នោត។

៦.សមាជិកនៃគណៈកម្មាធិការត្រូវជ្រើសរើសតាមការបោះឆ្នោតសម្រាប់ រយៈពេល ៤ឆ្នាំ ។ សមាជិកគណៈកម្មាធិការ អាចមានសិទ្ធិឈរឈ្មោះបោះ ឆ្នោតឡើងវិញ ប្រសិនបើមានការជ្រើសតាំងជាថ្មី។ អាណត្តិសមាជិក ៥រូប ក្នុងចំណោមសមាជិកជាប់ឆ្នោតលើកទី១ ត្រូវផុតកំណត់ក្នុងរយៈពេល ២ឆ្នាំ ហើយឈ្មោះរបស់សមាជិកទាំង៥រូបនេះ ត្រូវចាប់ឆ្នោតជាបន្ទាន់ដោយប្រធាន អង្គប្រជុំ ក្រោយពីការបោះឆ្នោតលើកទី១ ។

៧. ក្នុងគ្រាមានមរណភាព ឬការសុំលាឈប់ពីតំណែង ឬប្រកាសដោយបុព្វហេតុណាមួយថា មិនអាចបំពេញមុខងាររបស់ខ្លួនក្នុងគណៈកម្មាធិការនោះ រដ្ឋភាគីដែលបានជ្រើសតាំងសមាជិកនេះ ត្រូវតែងតាំងអ្នកជំនាញម្នាក់ផ្សេងទៀត ពីក្នុងចំណោមជនជាតិរបស់ខ្លួន ឱ្យបន្តបំពេញរយៈពេលនៃអាណត្តិដែលនៅសល់ ដោយមានការយល់ព្រមពីគណៈកម្មាធិការ ។

៨. គណៈកម្មាធិការ ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

៩. គណៈកម្មាធិការ ត្រូវជ្រើសរើសមន្ត្រីការិយាល័យរបស់ខ្លួនសម្រាប់រយៈពេល២ឆ្នាំ។

១០. សម័យប្រជុំណៈកម្មាធិការត្រូវធ្វើជាធម្មតានៅទីស្នាក់ការអង្គការសហប្រជាជាតិ ឬនៅកន្លែងសមស្របណាមួយផ្សេងទៀតដែលកំណត់ដោយគណៈកម្មាធិការ។ គណៈកម្មាធិការ ត្រូវរៀបចំសម័យប្រជុំប្រចាំឆ្នាំជាធម្មតា។ រយៈពេល នៃសម័យប្រជុំគណៈកម្មាធិការ ត្រូវកំណត់ ឬកែប្រែឡើងវិញបើចាំបាច់ ក្នុងសម័យប្រជុំមួយរបស់រដ្ឋភាគីនៃអនុសញ្ញានេះ ដោយមានការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ។

១១. អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវផ្តល់បុគ្គលិកនិងសម្ភារៈរូបវ័ន្តចាំបាច់ ដើម្បីឱ្យគណៈកម្មាធិការបំពេញមុខងារប្រកបដោយប្រសិទ្ធភាពស្របតាមអនុសញ្ញានេះ។

១២. ដោយមានការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ សមាជិកគណៈកម្មាធិការ ដែលបានបង្កើតឡើង ស្របតាមអនុសញ្ញានេះ ត្រូវទទួលបរិលាភពីធនធានរបស់អង្គការសហប្រជាជាតិ តាមលក្ខខណ្ឌ និងខទាំងឡាយដែលកំណត់ដោយមហាសន្និបាត។

## មាត្រា ៤៤

១. រដ្ឋភាគីរាប់រងដាក់ជូនគណៈកម្មាធិការ តាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិនូវរបាយការណ៍ស្តីពីវិធានការដែលបានប្រកាន់យក ដើម្បីធ្វើឱ្យសម្រេចនូវសិទ្ធិទាំងឡាយ ដែលបានទទួលស្គាល់ក្នុងអនុសញ្ញានេះ និងរបាយការណ៍ស្តីពីវឌ្ឍនភាព ក្នុងការអាស្រ័យផលពីសិទ្ធិទាំងនេះ :

(ក) ក្នុងរយៈពេល ២ឆ្នាំ ពីពេលដែលអនុសញ្ញានេះ ចូលជាធរមានសម្រាប់រដ្ឋភាគីពាក់ព័ន្ធ។

(ខ) បន្ទាប់មក រៀងរាល់ ៥ឆ្នាំម្តង។

២. របាយការណ៍ដែលធ្វើស្របតាមមាត្រានេះ ត្រូវបញ្ជាក់ពីកត្តា និងការលំបាក បើមាន ដែលនាំឱ្យប៉ះពាល់ដល់កម្រិតនៃការបំពេញកាតព្វកិច្ចក្រោមអនុសញ្ញានេះ ។ របាយការណ៍ ត្រូវបញ្ចូលព័ត៌មានឱ្យបានគ្រប់គ្រាន់ផងដែរ ដើម្បីផ្តល់ឱ្យគណៈកម្មាធិការ នូវការពន្យល់សព្វគ្រប់ អំពីការអនុវត្តអនុសញ្ញាក្នុងប្រទេសពាក់ព័ន្ធ។

៣. រដ្ឋភាគីដែលដាក់របាយការណ៍ពេញលេញលើកដំបូងជូនគណៈកម្មាធិការ មិនចាំបាច់សរសេរឡើងវិញ ក្នុងរបាយការណ៍បន្តបន្ទាប់របស់ខ្លួនដែលដាក់ជូនគណៈកម្មាធិការ ស្របតាមកថាខណ្ឌ១(ខ) នៃមាត្រានេះ នូវព័ត៌មានជាមូលដ្ឋានដែលមានក្នុងរបាយការណ៍មុនៗទេ។

៤. គណៈកម្មាធិការ អាចស្នើសុំព័ត៌មានបន្ថែមពីរដ្ឋភាគី ទាក់ទងនឹងការអនុវត្តអនុសញ្ញានេះ។

៥. គណៈកម្មាធិការ ត្រូវបញ្ជូនរបាយការណ៍ ស្តីពីសកម្មភាពរបស់ខ្លួនតាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទៅមហាសន្និបាតរៀងរាល់ ២ឆ្នាំម្តង។

៦. រដ្ឋភាគី ត្រូវធានាឱ្យមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់សាធារណជន នូវរបាយការណ៍របស់ខ្លួន នៅក្នុងប្រទេសខ្លួនផ្ទាល់។

មាត្រា ៤៥

ដើម្បីជំរុញឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្តអនុសញ្ញានេះ និងដើម្បីលើកទឹកចិត្ត ដល់កិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យដូចចែងក្នុងអនុសញ្ញានេះ :

(ក) ទីភ្នាក់ងារឯកទេស មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ និងស្ថាប័នផ្សេងទៀតនៃអង្គការសហប្រជាជាតិ មានសិទ្ធិតែងតាំងតំណាងដើម្បីត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញានេះ ក្នុងក្របខ័ណ្ឌនៃអាណត្តិរបស់ខ្លួន។ គណៈកម្មាធិការ អាចអញ្ជើញទីភ្នាក់ងារឯកទេស មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតដែលគណៈកម្មាធិការអាចនឹងយល់ថាសមស្រប ដើម្បីផ្តល់មតិឯកទេសស្តីពីការអនុវត្តអនុសញ្ញានេះ ក្នុងវិស័យដែលស្ថិតក្នុងក្របខ័ណ្ឌនៃអាណត្តិរបស់ខ្លួនរៀងៗខ្លួន។ គណៈកម្មាធិការ អាចអញ្ជើញទីភ្នាក់ងារឯកទេស មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ ឬស្ថាប័នផ្សេងទៀតរបស់អង្គការសហប្រជាជាតិ បញ្ជូនរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញានេះ ក្នុងវិស័យដែលស្ថិតក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន។

(ខ) បើយល់ថាចាំបាច់ គណៈកម្មាធិការត្រូវបញ្ជូនទៅទីភ្នាក់ងារឯកទេស មូលនិធិសហប្រជាជាតិដើម្បីកុមារ និងស្ថាប័នមានសមត្ថកិច្ចឯទៀត នូវរបាយការណ៍ណាមួយរបស់រដ្ឋភាគី ដែលមានភ្ជាប់នូវសេចក្តីស្នើសុំ ឬដែលបង្ហាញនូវសេចក្តីត្រូវការ ដើម្បីសុំជំនួយ ឬការណែនាំខាងបច្ចេកទេស ដោយភ្ជាប់ជាមួយនូវសេចក្តីសង្កេត និងការជូនយោបល់របស់គណៈកម្មាធិការ បើមានទៅលើការស្នើសុំ ឬការបង្ហាញខាងលើនេះ។

(គ) គណៈកម្មាធិការ អាចផ្ដល់អនុសាសន៍ទៅមហាសន្និបាត ដើម្បីសុំឱ្យអគ្គលេខាធិការចាត់ចែង ក្នុងនាមគណៈកម្មាធិការ ឱ្យមានការសិក្សាលើបញ្ហាពិសេសជាក់លាក់ពាក់ព័ន្ធនឹងសិទ្ធិកុមារ។

(ឃ) គណៈកម្មាធិការ អាចធ្វើការលើកសំណើ និងផ្ដល់អនុសាសន៍ទូទៅ ដោយផ្អែកលើមូលដ្ឋានព័ត៌មានដែលបានទទួល ស្របតាមមាត្រា៤៤ និងមាត្រា៤៥ នៃអនុសញ្ញានេះ។ សំណើ និងអនុសាសន៍ទូទៅទាំងនេះត្រូវបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ និងត្រូវរាយការណ៍ជូនមហាសន្និបាត ដោយភ្ជាប់ជាមួយនូវយោបល់របស់រដ្ឋភាគី ប្រសិនជាមាន។

## *ផ្នែកទី ៣*

### មាត្រា ៤៦

អនុសញ្ញានេះ ត្រូវបានបើកចំហឱ្យរដ្ឋទាំងអស់ចុះហត្ថលេខា។

### មាត្រា ៤៧

អនុសញ្ញានេះជាកម្មវត្ថុនៃការឱ្យសច្ចាប័ន។ លិខិតុបករណ៍នៃការឱ្យសច្ចាប័ន ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

### មាត្រា ៤៨

អនុសញ្ញានេះ នៅទុកបើកចំហឱ្យរដ្ឋទាំងអស់ សុំចូលជាសមាជិក ។ លិខិតុបករណ៍សុំចូលជាសមាជិក ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

### មាត្រា ៤៩

១. អនុសញ្ញានេះ ត្រូវចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ទី២០ នៃការឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

២. ចំពោះរដ្ឋនីមួយៗដែលឱ្យសច្ចាប័នឬសុំចូលជាសមាជិកនៃអនុសញ្ញានេះ ក្រោយពីការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកទី២០ អនុសញ្ញានេះ នឹងចូលជាធរមាន នៅថ្ងៃទី៣០ គិតចាប់ពីពេលដែលរដ្ឋនោះតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិករបស់ខ្លួន។

### មាត្រា ៥០

១. រដ្ឋភាគីណាមួយ អាចស្នើសុំធ្វើវិសោធនកម្ម និងដាក់សេចក្តីស្នើសុំធ្វើវិសោធនកម្មនេះ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ បន្ទាប់មកអគ្គលេខាធិការ ត្រូវបញ្ជូនសំណើធ្វើវិសោធនកម្ម ទៅរដ្ឋភាគីនានា ដោយសុំឱ្យរដ្ឋភាគីទាំងនោះបញ្ជាក់ថាតើ គាំទ្រឱ្យមានសន្និសីទនៃរដ្ឋភាគី ដើម្បីពិនិត្យនិងបោះឆ្នោតលើសេចក្តីស្នើសុំនោះដែរឬទេ។ បើក្នុងរយៈពេល៤ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការឆ្លើយឆ្លង មាន១ ភាគ ៣ យ៉ាងតិចនៃរដ្ឋភាគីគាំទ្រឱ្យមានសន្និសីទបែបនេះ អគ្គលេខាធិការ ត្រូវកោះធ្វើសន្និសីទ ក្រោមជំនួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ វិសោធនកម្មដែលអនុម័តដោយសម្លេងភាគច្រើននៃរដ្ឋភាគីវត្តមាន និងបានបោះឆ្នោតនៅក្នុងសន្និសីទ ត្រូវដាក់ជូនទៅមហាសន្និបាតដើម្បីសុំការយល់ព្រម។

២. វិសោធនកម្មដែលបានអនុម័ត ស្របតាមកថាខណ្ឌ១ នៃមាត្រានេះ ត្រូវចូលជាធរមាន នៅពេលបានទទួលការយល់ព្រមពី មហាសន្និបាតអង្គការសហប្រជាជាតិ និងទទួលបានការអនុម័តដោយសម្លេងភាគច្រើន ២ ភាគ ៣ នៃរដ្ឋភាគី។

៣. ពេលវិសោធនកម្ម ចូលជាធរមាន វិសោធនកម្មនេះ នឹងក្លាយជាកាតព្វកិច្ចសម្រាប់រដ្ឋភាគីដែលព្រមទទួលយក រដ្ឋភាគីដទៃទៀត ត្រូវស្ថិតនៅក្រោមបទ្បញ្ញត្តិ នៃអនុសញ្ញានេះ និងវិសោធនកម្មលើកមុន ដែលខ្លួនបានទទួលយក។

## មាត្រា ៥១

១. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវទទួល និងផ្សព្វផ្សាយទៅកាន់រដ្ឋទាំងអស់ នូវអត្ថបទនៃការដាក់លក្ខខណ្ឌរបស់រដ្ឋដែលធ្វើនៅពេលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក។

២. ការដាក់លក្ខខណ្ឌណាដែលវិសមភាពនឹងកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញានេះ មិនត្រូវបានអនុញ្ញាតឡើយ។

៣. ការដាក់លក្ខខណ្ឌ អាចដកវិញបានគ្រប់ពេលវេលា ដោយការជូនដំណឹងអំពីការដកខ្លួននេះ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយបន្ទាប់មក អគ្គលេខាធិការត្រូវជូនដំណឹងទៅរដ្ឋទាំងអស់។ ការជូនដំណឹងនេះមានអានុភាពចាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការបានទទួលការជូនដំណឹង។

## មាត្រា ៥២

១. រដ្ឋភាគីអាចប្រកាសដកខ្លួនចេញពីអនុសញ្ញានេះដោយការជូនដំណឹងជាលាយល័ក្ខអក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ការប្រកាសដកខ្លួនមាន អានុភាព ១ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទ ដែលអគ្គលេខាធិការបានទទួលការជូនដំណឹង។

## មាត្រា ៥៣

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបានតែងតាំងជាអ្នកទទួលរក្សាទុកអនុសញ្ញានេះ។

## មាត្រា ៥៤

ច្បាប់ដើមនៃអនុសញ្ញានេះ ដែលមានជាភាសាអារ៉ាប់ អង់គ្លេស បារាំង ចិន រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតម្លៃយថាភូតស្មើគ្នា និងត្រូវតំកល់ទុកនៅអគ្គលេខាធិការសហប្រជាជាតិ។

ជាបន្ទាល់នៃអនុសញ្ញានេះ អ្នកតំណាងពេញសមត្ថភាពដែលចុះហត្ថលេខាខាងក្រោម ដោយបានទទួលនូវការអនុញ្ញាតយ៉ាងត្រឹមត្រូវ បានចុះហត្ថលេខាលើអនុសញ្ញានេះ។

# ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ
# ពាក់ព័ន្ធនឹងការចូលរួមរបស់កុមារ
# ក្នុងជម្លោះប្រដាប់អាវុធ

*ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងសុំចូលជាសមាជិក*

តាមសេចក្តីសម្រេចចិត្តលេខA/RES/៥៤,២៦៣ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០០

របស់មហាសន្និបាតអង្គការសហប្រជាជាតិ

ចូលជាធរមាននៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០២ ស្របតាមមាត្រា១០

*រដ្ឋភាគីនៃពិធីសារនេះ :*

*ត្រូវបានលើកទឹកចិត្ត* ដោយការគាំទ្រដ៏ច្រើនលើសលប់ចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបង្ហាញឱ្យឃើញនូវការប្តេជ្ញាចិត្តកាន់តែច្រើនឡើងៗ ក្នុងការខិតខំលើកស្ទួយ និងការពារសិទ្ធិកុមារ។

*ប្រកាសបញ្ជាក់ជាថ្មីថា* សិទ្ធិកុមារត្រូវការនូវការការពារពិសេស និង*អំពាវនាវសុំឱ្យ* បន្តលើកកំពស់ស្ថានភាពកុមារ ដោយគ្មានការប្រកាន់បែងចែក និងឱ្យមានការអភិវឌ្ឍន៍ និងការអប់រំដល់កុមារក្នុងលក្ខខណ្ឌសន្តិភាពនិងសន្តិសុខ។

*ត្រូវបានរំខាន* ដោយផលប៉ះពាល់នៃជម្លោះប្រដាប់អាវុធដែលរាលដាល និងធ្វើឱ្យខូចខាតដល់កុមារ និងដោយផលវិបាករយៈពេលវែង សម្រាប់សន្តិភាព សន្តិសុខ និងការអភិវឌ្ឍន៍ស្ថិតស្ថេរ។

*ផ្តន្ទាទោស* ចំពោះការដាក់កុមារជាមុខសញ្ញា ក្នុងស្ថានភាពនៃជម្លោះប្រដាប់អាវុធ និងការវាយប្រហារដោយផ្ទាល់ ទៅលើវត្ថុដែលត្រូវទទួលបានការការពារក្រោមច្បាប់អន្តរជាតិ រាប់ទាំងទីកន្លែងដែលជាទូទៅ មានវត្តមានកុមារ មានជាអាទិ៍ សាលារៀន និងមន្ទីរពេទ្យ។

*កត់សំគាល់* ការអនុម័តលក្ខន្តិកៈក្រុងរ៉ូមស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងជាពិសេស ការរាប់បញ្ចូលជាបទឧក្រិដ្ឋសង្គ្រាម នៅក្នុងលក្ខន្តិកៈនូវការកេណ្ឌ ឬចុះបញ្ជី ជ្រើសរើសកុមារក្រោមអាយុ១៥ឆ្នាំ ឱ្យធ្វើទាហាន ឬឱ្យចូលរួមយ៉ាងសកម្មក្នុងអរិភាព ក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ និងមិនមែនអន្តរជាតិ។

*យល់ឃើញថា* ដើម្បីពង្រឹងបន្ថែមនូវការអនុវត្តសិទ្ធិដែលទទួលស្គាល់ក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ គឺចាំបាច់ត្រូវបង្កើនការការពារកុមារ មិនឱ្យចូលពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ។

*កត់សំគាល់ឃើញថា* មាត្រា១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ បញ្ជាក់ច្បាស់លាស់ថា សម្រាប់គោលបំណងនៃអនុសញ្ញានេះ កុមារគឺជាមនុស្សមានអាយុក្រោម ១៨ឆ្នាំ លើកលែងតែច្បាប់ដែលអនុវត្តចំពោះកុមារ កំណត់អំពីនីតិភាពទាបជាងនេះ។

*ជឿជាក់ថា* ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារដែលតម្លើងអាយុបុគ្គល ដែលអាចជ្រើសរើសឱ្យចូលបម្រើក្នុងកងកម្លាំងប្រដាប់អាវុធ និងចូលរួមក្នុងអរិភាព នឹងរួមចំណែកយ៉ាងមានប្រសិទ្ធភាពដល់ការអនុវត្តគោលការណ៍ដែលត្រូវគិតគូរជាចម្បងដល់ឧត្តមប្រយោជន៍របស់កុមារ នៅគ្រប់សកម្មភាពដែលពាក់ព័ន្ធនឹងកុមារ។

*កត់សំគាល់ឃើញថា* សន្និសីទអន្តរជាតិលើកទី២៦ នៃកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ក្នុងខែធ្នូ ឆ្នាំ១៩៩៥ បានធ្វើអនុសាសន៍ ដែលមានជាអាទិ៍ថា ភាគីនៃជម្លោះត្រូវចាត់រាល់វិធានការដែលអាចធ្វើទៅបាន ដើម្បីធានាមិនឱ្យកុមារអាយុក្រោម ១៨ឆ្នាំ ចូលរួមក្នុងអរិភាព។

*ស្វាគមន៍* ការអនុម័តជាឯកច្ឆ័ន្ទ ក្នុងខែមិថុនា ឆ្នាំ១៩៩៩ ដោយអង្គការពលកម្មអន្តរជាតិ(ILO) នូវអនុសញ្ញាលេខ១៨២ស្តីពីការហាមប្រាម និងការចាត់វិធានការបន្ទាន់ ដើម្បីលប់បំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ដែលមានជាអាទិ៍ ការហាមឃាត់ការជ្រើសរើសកុមារដោយការបង្ខិតបង្ខំ ឬជាកាតព្វកិច្ច ដើម្បីប្រើប្រាស់ក្នុងជម្លោះប្រដាប់អាវុធ។

*ថ្កោលទោសយ៉ាងធ្ងន់ធ្ងរបំផុត* ចំពោះការជ្រើសរើស ការហ្វឹកហ្វឺន និងការប្រើប្រាស់កុមារក្នុងដែនដីជាតិ ឬឆ្លងដែនដីជាតិនៅក្នុងអរិភាព ដោយក្រុមប្រដាប់អាវុធ ផ្សេងពីកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ និង*ទទួលស្គាល់* ការទទួលខុសត្រូវរបស់ជនដែលជ្រើសរើស ហ្វឹកហ្វឺន និងប្រើប្រាស់កុមារនៅក្នុងគោលដៅខាងលើនេះ។

*រំលឹកឡើងវិញ* អំពីកាតព្វកិច្ចរបស់ភាគីនីមួយៗនៃជម្លោះប្រដាប់អាវុធក្នុងការអនុវត្តបទប្បញ្ញត្តិនៃច្បាប់មនុស្សធម៌អន្តរជាតិ។

*សង្កត់ធ្ងន់ថា*ពិធីសារនេះមិនប៉ះពាល់ដល់គោលបំណង និងគោលការណ៍ដូចមានកំណត់ក្នុងធម្មនុញ្ញសហប្រជាជាតិ រួមមានមាត្រា៥១ ផង និងបទដ្ឋាននានានៃច្បាប់មនុស្សធម៌អន្តរជាតិឡើយ។

*ចងចាំថា* លក្ខខណ្ឌសន្តិភាព និងសន្តិសុខ ដែលផ្អែកលើការគោរពទាំងស្រុងនូវគោលបំណង និងគោលការណ៍ដូចបានកំណត់ក្នុងធម្មនុញ្ញសហប្រជាជាតិ និង*ចងចាំថា* ការប្រតិបត្តិតាមលិខិតុបករណ៍សិទ្ធិមនុស្សជាធរមាន គឺមិនអាចខ្វះបានឡើយ ដើម្បីការពារកុមារឱ្យបានទាំងស្រុង ជាពិសេស អំឡុងពេលមានជម្លោះប្រដាប់អាវុធ និងការកាន់កាប់ដោយបរទេស។

*ទទួលស្គាល់* សេចក្តីត្រូវការពិសេសរបស់កុមារ ដែលជាពិសេសងាយទទួលរងគ្រោះដោយសារការជ្រើសរើស ឬប្រើប្រាស់នៅក្នុងអរិភាព ផ្ទុយនឹងពិធីសារនេះ ដោយហេតុមកពីស្ថានភាពសេដ្ឋកិច្ច ឬស្ថានភាពសង្គម ឬភេទ។

*កត់សំគាល់អំពី* ភាពចាំបាច់ ដើម្បីពិនិត្យពិចារណារកមូលហេតុជាឫសគល់ខាងសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ ក្នុងការធ្វើឱ្យកុមារពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ។

*មានជំនឿ* លើភាពចាំបាច់ដើម្បីពង្រឹងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តពិធីសារនេះ ព្រមទាំងការស្តារសម្បទាខាងផ្លូវកាយ និងផ្លូវចិត្ត និងការធ្វើសមាហរណកម្មកុមាររងគ្រោះនៃជម្លោះប្រដាប់អាវុធទៅក្នុងសង្គម ។

*លើកទឹកចិត្ត* ដល់ការចូលរួមរបស់សហគមន៍ ជាពិសេសកុមារ និងកុមាររងគ្រោះ ក្នុងការផ្សព្វផ្សាយកម្មវិធីអប់រំ និងកម្មវិធីព័ត៌មានស្តីពីការអនុវត្តពិធីសារនេះ។

*បានព្រមព្រៀងគ្នាដូចតទៅ :*

មាត្រា ១

រដ្ឋភាគីត្រូវចាត់វាល់វិធានការទាំងអស់តាមដែលអាចធ្វើបាន ដើម្បីធានាថា សមាជិកកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនដែលអាយុមិនគ្រប់ ១៨ឆ្នាំ មិនចូលរួមដោយផ្ទាល់ក្នុងអរិភាពឡើយ។

មាត្រា ២

រដ្ឋភាគីត្រូវធានាថា បុគ្គលមិនគ្រប់អាយុ ១៨ឆ្នាំ មិនត្រូវបានជ្រើសរើសឱ្យចូលក្នុងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋជាដាច់ខាត។

មាត្រា ៣

១. រដ្ឋភាគីត្រូវតំឡើងអាយុអប្បបរមា សម្រាប់ការជ្រើសរើសអ្នកស្ម័គ្រចិត្តចូលបម្រើកងកម្លាំងប្រដាប់អាវុធជាតិរបស់ខ្លួន ឱ្យខ្ពស់ជាងអាយុដែលមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៣៨ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដោយគិតដល់គោលការណ៍ដែលមានកំណត់ក្នុងមាត្រានោះ និងដោយទទួលស្គាល់ថាយោងតាមអនុសញ្ញានោះ បុគ្គលដែលមានអាយុក្រោម ១៨ឆ្នាំ មានសិទ្ធិទទួលបាននូវការការពារពិសេស។

២. រដ្ឋភាគីនីមួយៗនៅពេលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកនៃពិធីសារនេះ ត្រូវតំកល់សេចក្តីប្រកាសខ្ជាប់មួយ ស្តីពីការកំណត់អាយុអប្បបរមាដែលអនុញ្ញាតឱ្យជ្រើសរើសដោយស្ម័គ្រចិត្ត ចូលបម្រើក្នុងកងកម្លាំងប្រដាប់អាវុធជាតិរបស់ខ្លួន និងត្រូវតំកល់សេចក្តីពណ៌នាពីវិធានការការពារដែលរដ្ឋភាគីបានអនុម័ត ដើម្បីធានាថា មិនមានការជ្រើសរើសដោយបង្ខិតបង្ខំ ឬដោយប្រើកំលាំង។

៣. រដ្ឋភាគី ដែលអនុញ្ញាតឱ្យជ្រើសរើសបុគ្គលមានអាយុក្រោម ១៨ឆ្នាំ ឱ្យចូលបម្រើដោយស្ម័គ្រចិត្តក្នុងកងកម្លាំងប្រដាប់អាវុធជាតិរបស់ខ្លួន ត្រូវធានាឱ្យបានជាអប្បបរមាថា :

(ក) ការជ្រើសរើស ធ្វើតាមការស្ម័គ្រចិត្តពិតប្រាកដ។

(ខ) ការជ្រើសរើសធ្វើឡើងដោយមានការយល់ព្រមពីឪពុក-ម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់ជននោះ បន្ទាប់ពីបានទទួលដំណឹងពីផលប៉ះពាល់នានា។

(គ) បុគ្គលនោះ ត្រូវទទួលបានព័ត៌មានពេញលេញ ស្ដីពីករណីយកិច្ចចូលរួមបម្រើកងទ័ព។

(ឃ) បុគ្គលនោះ ត្រូវផ្ដល់ភស្ដុតាងសមស្របអំពីអាយុរបស់ខ្លួន មុនទទួលឱ្យចូលបម្រើកងទ័ពជាតិ។

៤. រដ្ឋភាគីនីមួយៗ អាចពង្រឹងសេចក្ដីប្រកាសរបស់ខ្លួនបានគ្រប់ពេល ដោយជូនដំណឹងអំពីកិច្ចការនេះ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវជូនដំណឹងអំពីការពង្រឹងនេះ ទៅរដ្ឋភាគីទាំងអស់។ ការជូនដំណឹងនេះ មានអនុភាពចាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបាននូវសេចក្ដីជូនដំណឹងនោះ។

៥. ការតម្រូវឱ្យតំឡើងអាយុក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ មិនអនុវត្តចំពោះសាលារៀនដែលដំណើរការ ឬត្រួតពិនិត្យដោយកងកម្លាំងប្រដាប់អាវុធនៃរដ្ឋភាគីឡើយ ដោយប្រកាន់ខ្ជាប់តាមមាត្រា២៨ និងមាត្រា២៩ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ។

## មាត្រា ៤

១. ក្រុមប្រដាប់អាវុធ ក្រៅពីកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ មិនត្រូវជ្រើសរើស ឬប្រើប្រាស់បុគ្គលអាយុក្រោម ១៨ឆ្នាំ ក្នុងអរិភាពឡើយ។

២. រដ្ឋភាគីត្រូវចាត់រាល់វិធានការតាមដែលអាចធ្វើបាន ដើម្បីទប់ស្កាត់ការជ្រើសរើស និងការប្រើបែបនេះ រួមមាន ការអនុម័តវិធានការច្បាប់ដែលចាំបាច់ដើម្បីហាមឃាត់ និងដាក់ជាបទព្រហ្មទណ្ឌចំពោះការប្រព្រឹត្តបែបនេះ។

៣. ការអនុវត្តមាត្រានេះ មិនប៉ះពាល់ឋានៈខាងផ្លូវច្បាប់នៃភាគីណាមួយក្នុងជម្លោះប្រដាប់អាវុធឡើយ។

## មាត្រា ៥

គ្មានបទប្បញ្ញត្តិណាមួយឡើយនៃពិធីសារនេះ អាចយកមកបកស្រាយថាជាការរារាំងដល់ការអនុវត្តបទប្បញ្ញត្តិនៃច្បាប់របស់រដ្ឋភាគី ឬលិខិតុបករណ៍អន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិដែលអាចមានប្រយោជន៍ ប្រសើរជាងនេះ ក្នុងការធ្វើឱ្យសម្រេចបាននូវសិទ្ធិកុមារ។

## មាត្រា ៦

១. រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់តាមផ្លូវច្បាប់ តាមផ្លូវរដ្ឋបាល និងវិធានការផ្សេងៗទៀត ដើម្បីធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទប្បញ្ញត្តិនៃពិធីសារនេះ ក្នុងយុត្តាធិការរបស់ខ្លួន។

២. រដ្ឋភាគីរ៉ាប់រងផ្សព្វផ្សាយគោលការណ៍ និងបទប្បញ្ញត្តិនៃពិធីសារនេះ ដល់មនុស្សពេញវ័យ និងកុមារឱ្យបានយល់ដឹងទូលំទូលាយ និងជំរុញឱ្យអ្នកទាំងនោះអនុវត្តតាមមធ្យោបាយសមស្របនានា ។

៣. រដ្ឋភាគីត្រូវចាត់រាល់វិធានការដែលអាចធ្វើបាន ដើម្បីធានាថាបុគ្គលរស់នៅក្នុងយុត្តាធិការរបស់ខ្លួន ដែលបានជ្រើសរើស ឬប្រើក្នុងអរិភាពដែលផ្ទុយពីខ្លឹមសារនៃពិធីសារនេះ ត្រូវបានរំសាយ ឬឱ្យរួចផុតពីការបម្រើទ័ព។ករណីចាំបាច់ រដ្ឋភាគីត្រូវផ្តល់ជំនួយឧបត្ថម្ភសមស្របដល់អ្នកទាំងនោះដើម្បីស្តារសម្បទាខាងផ្លូវកាយ និងផ្លូវចិត្ត និងធ្វើសមាហរណកម្មទៅក្នុងសង្គម។

## មាត្រា ៧

១. រដ្ឋភាគី ត្រូវធ្វើសហប្រតិបត្តិការជាមួយគ្នាដែលក្នុងនោះ រួមមានសហប្រតិបត្តិការបច្ចេកទេស និងជំនួយឧបត្ថម្ភខាងហិរញ្ញវត្ថុផងក្នុងការអនុវត្តពិធីសារនេះ ក្នុងនោះមាន ការបង្ការសកម្មភាពផ្ទុយពីពិធីសារនេះ និងការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មក្នុងសង្គមនូវជនរងគ្រោះពីអំពើផ្ទុយពីពិធីសារនេះ។ ជំនួយឧបត្ថម្ភ និងសហប្រតិបត្តិការនេះ នឹងត្រូវអនុម័តតាមរយៈការពិគ្រោះយោបល់ជាមួយរដ្ឋភាគី និងអង្គការអន្តរជាតិពាក់ព័ន្ធ។

២. រដ្ឋភាគីដែលស្ថិតក្នុងនាទីផ្តល់ជំនួយឧបត្ថម្ភ ត្រូវផ្តល់ជំនួយនេះតាមរយៈកម្មវិធីពហុភាគី ទ្វេភាគី ឬកម្មវិធីផ្សេងទៀតដែលមានស្រាប់ ឬពុំនោះទេតាមរយៈមូលនិធិនៃវិភាគទានស្ម័គ្រចិត្ត ដែលបង្កើត ស្របតាមបែបបទនៃមហាសន្និបាតអង្គការសហប្រជាជាតិជាអាទិ៍។

## មាត្រា ៨

១. រដ្ឋភាគីនីមួយៗ ក្នុងរយៈពេល ២ឆ្នាំ ក្រោយពីពិធីសារនេះចូលជាធរមានចំពោះខ្លួន ត្រូវដាក់របាយការណ៍មួយ ជូនគណៈកម្មាធិការសិទ្ធិកុមារ ដោយផ្តល់ព័ត៌មានលំអិតស្តីពីវិធានការរបស់រដ្ឋភាគី ក្នុងការអនុវត្តបទប្បញ្ញត្តិនៃពិធីសារនេះ រួមមាន វិធានការអនុវត្តបទប្បញ្ញត្តិស្តីពីការចូលបម្រើទ័ព និងការជ្រើសរើសទ័ពផង។

២. បន្ទាប់ពីដាក់របាយការណ៍លំអិត រដ្ឋភាគីនីមួយៗត្រូវបញ្ចូលព័ត៌មានបន្ថែមស្តីពីការអនុវត្តពិធីសារនេះ ក្នុងរបាយការណ៍ ជូនទៅគណៈកម្មាធិការសិទ្ធិកុមារ ដូចមានចែងក្នុងមាត្រា៤៤ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ រដ្ឋភាគីឯទៀតនៃពិធីសារនេះ ត្រូវដាក់របាយការណ៍រៀងរាល់ ៥ឆ្នាំម្តង។

៣. គណៈកម្មាធិការសិទ្ធិកុមារអាចស្នើសុំឱ្យរដ្ឋភាគីផ្ដល់ព័ត៌មានបន្ថែមទាក់ទងនឹងការអនុវត្តពិធីសារនេះ។

## មាត្រា ៩

១. ពិធីសារនេះ បើកចំហឱ្យចុះហត្ថលេខាសម្រាប់រដ្ឋដែលជាភាគីនៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ ឬដែលបានចុះហត្ថលេខាលើអនុសញ្ញាស្ដីពីសិទ្ធិកុមារ។

២. ពិធីសារនេះ ជាកម្មវត្ថុនៃការឱ្យសច្ចាប័ន និងបើកចំហឱ្យរដ្ឋសុំចូលជាសមាជិក។ លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៣. អគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងឋានៈជាអ្នកទទួលទុកអនុសញ្ញាស្ដីពីសិទ្ធិកុមារ និងពិធីសារ ត្រូវជូនដំណឹងដល់រដ្ឋភាគីទាំងអស់នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញាស្ដីពីសិទ្ធិកុមារ អំពីលិខិតុបករណ៍នៃសេចក្ដីប្រកាសនីមួយៗ ស្របតាមមាត្រា៣។

## មាត្រា ១០

១. ពិធីសារនេះចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកទី១០។

២. ចំពោះរដ្ឋនីមួយៗដែលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក បន្ទាប់ពីពិធីសារនេះចូលជាធរមាន ពិធីសារនេះត្រូវចូលជាធរមានក្នុងរយៈពេល១ខែ បន្ទាប់ពីកាលបរិច្ឆេទ នៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិករបស់រដ្ឋនោះ។

## មាត្រា ១១

១. រដ្ឋភាគីអាចប្រកាសដកខ្លួនចេញពីពិធីសារនេះបានគ្រប់ពេល ដោយការជូនដំណឹងជាលាយល័ក្ខអក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការ ត្រូវជូនដំណឹងពីការប្រកាសដកខ្លួននេះ ទៅរដ្ឋភាគីផ្សេងទៀតនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ការប្រកាសដកខ្លួនមានអនុភាពក្នុងរយៈពេល១ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបានការជូនដំណឹង។ ប៉ុន្តែបើផុតកំណត់រយៈពេល១ឆ្នាំនេះ រដ្ឋភាគីដែលប្រកាសដកខ្លួននោះ ជាប់ពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធនោះ ការប្រកាសរំសាយនេះ មិនចូលជាធរមានមុនចប់ជម្លោះប្រដាប់អាវុធឡើយ។

២. ការប្រកាសដកខ្លួននេះ ពុំមានអានុភាពឱ្យរដ្ឋភាគីរួចផុតពីកាតព្វកិច្ចរបស់ខ្លួន ក្រោមពិធីសារនេះ ចំពោះបទល្មើសណាដែលកើតមុនកាលបរិច្ឆេទនៃការប្រកាសដកខ្លួនចូលជាធរមានឡើយ។ ទោះតាមមធ្យោបាយណាក៏ដោយ ការប្រកាសដកខ្លួននេះ មិនប៉ះពាល់ដល់ការបន្តពិនិត្យបញ្ហាទាំងឡាយ ដែលគណៈកម្មាធិការសិទ្ធិកុមារកំពុងពិនិត្យ មុនកាលបរិច្ឆេទប្រកាសដកខ្លួនចូលជាធរមានឡើយ។

## មាត្រា ១២

១. រដ្ឋភាគី អាចសុំធ្វើវិសោធនកម្ម និងដាក់សេចក្តីស្នើសុំនេះ ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការត្រូវបញ្ជូនសេចក្តីស្នើវិសោធនកម្មទៅរដ្ឋភាគី ដោយស្នើសុំឱ្យរដ្ឋភាគីបញ្ជាក់ថាតើ រដ្ឋភាគីយល់ព្រមឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ ដើម្បីពិនិត្យ និងបោះឆ្នោតលើសេចក្តីស្នើ

សុំឬទេ។ ក្នុងរយៈពេល៤ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការឆ្លើយឆ្លងនោះ ក្នុងករណីមានសំឡេង១ភាគ៣យ៉ាងតិចនៃរដ្ឋភាគី គាំទ្រឱ្យមានសន្និសីទបែបនេះ អគ្គលេខាធិការត្រូវកោះធ្វើសន្និសីទ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ វិសោធនកម្ម ដែលបានអនុម័តដោយមតិភាគច្រើននៃរដ្ឋភាគីវត្តមាន និងបានបោះឆ្នោតក្នុងសន្និសីទ ត្រូវដាក់ជូនមហាសន្និបាតសហប្រជាជាតិដើម្បីសុំការយល់ព្រម។

២. វិសោធនកម្មដែលបានអនុម័ត ស្របតាមកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវចូលជាធរមាន នៅពេលវិសោធនកម្មនេះ ទទួលបានការយល់ព្រមពីមហាសន្និបាត និងបានទទួលយកដោយមតិភាគច្រើន ២ភាគ៣ នៃរដ្ឋភាគី។

៣. នៅពេលវិសោធនកម្មចូលជាធរមានហើយ វិសោធនកម្មនោះ នឹងក្លាយជាកាតព្វកិច្ចសម្រាប់រដ្ឋភាគី ដែលយល់ព្រមទទួលយកវិសោធនកម្មនោះ រដ្ឋភាគីក្រៅពីនេះ នៅតែជាប់កាតព្វកិច្ចចំពោះបទប្បញ្ញត្តិនៃពិធីសារនេះ និងវិសោធនកម្មមុនៗដែលរដ្ឋភាគីនោះបានយល់ព្រមទទួលយក។

### មាត្រា ១៣

១. ពិធីសារនេះ ដែលមានអត្ថបទជាភាសាអារ៉ាប់ អង់គ្លេស បារាំង ចិន រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតម្លៃយថាភូតស្មើគ្នា និងត្រូវដំកល់ទុកនៅបណ្ណសារដ្ឋាននៃអង្គការសហប្រជាជាតិ។

២. អគ្គលេខាធិការសហប្រជាជាតិត្រូវបញ្ជូនសេចក្តីចម្លងនៃពិធីសារនេះ ដោយមានបញ្ជាក់ការចម្លងស្របតាមច្បាប់ដើម ជូនរដ្ឋភាគីទាំងអស់ នៃអនុសញ្ញា និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។

# ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ

ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ន និងសុំចូលជាសមាជិក
ដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ
តាមសេចក្តីសម្រេចចិត្តលេខ:A/RES/៥៤/២៦៣ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០០
ចូលជាធរមាននៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០២ ស្របតាមមាត្រា១៤

*រដ្ឋភាគីនៃពិធីសារនេះ*

*យល់ឃើញថា* ដើម្បីធ្វើឱ្យសម្រេចគោលបំណងនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ *និង*ការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ពិសេសមាត្រា១ មាត្រា១១ មាត្រា២១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ និង មាត្រា៣៦ ឱ្យកាន់តែបានច្រើន ការពង្រីកវិធានការ គឺជាការសមស្របនឹងការសន្យារបស់រដ្ឋភាគី ដើម្បីធានា ការពារកុមារប្រឆាំងនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ។

*យល់ឃើញផងដែរថា* អនុសញ្ញាស្តីពីសិទ្ធិកុមារទទួលស្គាល់សិទ្ធិកុមារទទួលការការពារប្រឆាំងនឹងការកេងប្រវ័ញ្ចសេដ្ឋកិច្ច និងការឱ្យធ្វើការងារដែលគ្រោះថ្នាក់ ឬការងារដែលប៉ះពាល់ដល់ការសិក្សារបស់កុមារ ឬធ្វើឱ្យខូចសុខភាពកុមារ ឬការអភិវឌ្ឍន៍ខាងផ្លូវកាយ ផ្លូវចិត្ត ស្មារតី សីលធម៌ ឬសង្គម។

*មានកង្វល់យ៉ាងខ្លាំង* ចំពោះកំណើនច្រើនឡើងគួរឱ្យកត់សំគាល់នៃការជួញដូរកុមារជាអន្តរជាតិ ដើម្បីលក់កុមារ ពេស្យាកម្មកុមារ និងរូបភាព ឬសម្ភារៈអាសអាភាសកុមារ។

*មានការបារម្ភយ៉ាងជ្រាលជ្រៅ* ចំពោះការអនុវត្តយ៉ាងរីករាលដាល និងជាបន្តនៃទេសចរណ៍ផ្លូវភេទ ដែលកុមារងាយរងគ្រោះច្រើនជាងគេ ដោយហេតុថា ទេសចរណ៍ផ្លូវភេទជំរុញដោយផ្ទាល់ ឱ្យមានការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ។

*ទទួលស្គាល់ថា* ក្រុមជាច្រើនដែលងាយរងគ្រោះជាពិសេស ដែលក្នុងនោះរួមមានកុមារី គឺស្ថិតក្នុងចំណុចគ្រោះថ្នាក់ នៃការកេងប្រវ័ញ្ចផ្លូវភេទខ្លាំងជាងគេ និង*ទទួលស្គាល់ថា* កុមារីស្ថិតក្នុងតួលេខខ្ពស់ហួសហេតុ ក្នុងចំណោមអ្នករងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទ។

*មានកង្វល់* ចំពោះភាពងាយរកបានច្រើនឡើងនៃរូបភាពអាសអាភាសកុមារតាមអ៊ីនធឺណែត និងបច្ចេកវិទ្យាផ្សេងទៀតដែលកំពុងវិវត្ត និង*រំលឹកឡើងវិញ* អំពីសន្និសីទអន្តរជាតិ ធ្វើនៅទីក្រុងវីយែន ក្នុងឆ្នាំ១៩៩៩ ស្តីពីការប្រយុទ្ធប្រឆាំងនឹងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារតាមអ៊ីនធឺណែត ជាពិសេស សេចក្តីសន្និដ្ឋាននៃសន្និសីទនេះ អំពាវនាវឱ្យពិភពលោកទាំងមូលដាក់ជាបទឧក្រិដ្ឋចំពោះការផលិត ការចែកចាយ ការនាំចេញ ការបញ្ជូន ការនាំចូល ការកាន់កាប់ដោយចេតនា និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ និងសង្កត់ធ្ងន់លើសារសំខាន់នៃកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរជិតស្និទ្ធរវាងរដ្ឋាភិបាល និងឧស្សាហកម្មអ៊ីនធឺណែត។

*ជឿជាក់ថា* ការលុបបំបាត់ការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ នឹងត្រូវបានសម្រួល តាមរយៈការអនុម័តយកវិធីសាស្ត្រ ចម្រុះផ្តែកព្រមគ្នា ដោយដោះស្រាយកត្តារួមចំណែក មានជាអាទិ៍ភាពខិនថយ ភាពក្រីក្រ គម្លាតខាងសេដ្ឋកិច្ច រចនាសម្ព័នខាងសង្គម និង

សេដ្ឋកិច្ច ដែលមានវិសមធម៌ ភាពមិនប្រក្រតីនៃគ្រួសារ កង្វះខាតខាងការអប់រំ ការផ្លាស់ទីលំនៅពីជនបទមកទីក្រុង ការរើសអើងភេទ ការប្រព្រឹត្តខាងផ្លូវភេទ របស់មនុស្សពេញវ័យដែលគ្មានការទទួលខុសត្រូវ ការអនុវត្តជាទម្លាប់ប្រកបដោយគ្រោះថ្នាក់ ជម្លោះប្រដាប់អាវុធ និងការជួញដូរកុមារ។

*ជឿជាក់ផងដែរថា* ការខិតខំលើកកំពស់ការយល់ដឹងជាសាធារណៈគឺជាការចាំបាច់ ដើម្បីកាត់បន្ថយតម្រូវការរបស់អតិថិជន ចំពោះការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ និង*មានជំនឿ* លើសារសំខាន់នៃការពង្រឹងភាពជាដៃគូនៅទូទាំងពិភពលោក ជាមួយតួអង្គទាំងអស់ និងការលើកកំពស់ការអនុវត្តច្បាប់ថ្នាក់ជាតិ។

*កត់សំគាល់* បទប្បញ្ញត្តិនៃលិខិតុបករណ៍គតិយុត្តិអន្តរជាតិពាក់ព័ន្ធនឹងការការពារកុមារ រួមមាន អនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការសុំកូនអន្តរប្រទេស អនុសញ្ញាក្រុងឡាអេស្តីពីទិដ្ឋភាពរដ្ឋប្បវេណីនៃការចាប់ពង្រត់កុមារជាលក្ខណៈអន្តរជាតិ អនុសញ្ញាក្រុងឡាអេស្តីពីដែនសមត្ថកិច្ចច្បាប់ដែលអាចអនុវត្តបាន ការទទួលស្គាល់ ការអនុវត្ត និងសហប្រតិបត្តិការលើការទទួលខុសត្រូវរបស់ឪពុក-ម្តាយ និងវិធានការសម្រាប់ការពារកុមារ និងអនុសញ្ញាលេខ១៨២ របស់អង្គការពលកម្មអន្តរជាតិស្តីពីការហាមឃាត់ និងវិធានការបន្ទាន់ ដើម្បីលប់បំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។

*បានទទួលការលើកទឹកចិត្ត* ដោយការគាំទ្រដ៏ច្រើនលើសលប់ លើអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបញ្ជាក់ឱ្យឃើញនូវការប្តេជ្ញាកាន់តែទូលំទូលាយក្នុងការលើកស្ទួយ និងការពារសិទ្ធិកុមារ។

*ទទួលស្គាល់* សារៈប្រយោជន៍នៃការអនុវត្តបទប្បញ្ញត្តិនៃកម្មវិធីសកម្មភាព ដើម្បីបង្ការការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ និងសេចក្តីប្រកាស និងកម្មវិធីសកម្មភាពដែលបានអនុម័តក្នុងសមាជពិភពលោកប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក្នុងគោលដៅពាណិជ្ជកម្ម ធ្វើនៅទីក្រុងស្តុកខុម ពីថ្ងៃទី២៧ ដល់៣១ ខែសីហា ឆ្នាំ១៩៩៦ និងសេចក្តីសម្រេច និងអនុសាសន៍សមស្របផ្សេងទៀត របស់អង្គការអន្តរជាតិដែលពាក់ព័ន្ធ។

*គិតគូរ* អំពីសារៈសំខាន់នៃប្រពៃណី និងតម្លៃខាងវប្បធម៌របស់ប្រជាពលរដ្ឋម្នាក់ៗ ក្នុងការការពារកុមារ និងក្នុងការធ្វើឱ្យកុមារមានការរីកចម្រើនដោយសុខដុម។

*បានព្រមព្រៀងគ្នាដូចតទៅ :*

មាត្រា ១

រដ្ឋភាគី ត្រូវហាមឃាត់ការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាពឬសម្ភារៈអាសអាភាសកុមារ ដូចបានកំណត់ដោយពិធីសារនេះ។

មាត្រា ២

សម្រាប់គោលបំណងនៃពិធីសារនេះ :

(ក) ការលក់កុមារ គឺជាអំពើ ឬកិច្ចការជំនួញរបស់មនុស្សណាម្នាក់ ឬក្រុមមនុស្សណាមួយ ដើម្បីផ្ទេរកុមារទៅមនុស្សម្នាក់ទៀត ឬក្រុមមនុស្សមួយទៀត បំណងយកកម្រៃ ឬអត្ថប្រយោជន៍ផ្សេងទៀត។

(ខ) ពេស្យាកម្មកុមារ គឺជាការប្រើប្រាស់កុមារក្នុងសកម្មភាពផ្លូវភេទ បំណងយកកម្រៃ ឬអត្ថប្រយោជន៍តាមទម្រង់ផ្សេងៗ។

(គ) រូបភាពឬសម្ភារៈអាសអាភាសកុមារ គឺជាការបង្ហាញទាំងឡាយ ទោះតាមមធ្យោបាយអ្វីក៏ដោយ អំពីសកម្មភាពរួមភេទជារូបពិត ឬដោយការចម្លងរូបភាពពិត ឬការបង្ហាញអវយវៈភេទរបស់កុមារ សម្រាប់គោលបំណងចម្បងខាងផ្លូវភេទ។

## មាត្រា ៣

១. រដ្ឋភាគីនីមួយៗ ត្រូវធានាជាអប្បបរមាថា អំពើ និងសកម្មភាពខាងក្រោមនេះ ត្រូវទទួលការផ្តន្ទាទោសយ៉ាងពេញលេញ ក្រោមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ទោះជាបទល្មើសទាំងនោះ ត្រូវបានប្រព្រឹត្តនៅក្នុងប្រទេស ឬឆ្លងប្រទេស ឬជាលក្ខណៈបុគ្គល ឬជាលក្ខណៈចាត់តាំងក៏ដោយ :

(ក) ក្នុងបរិបទស្តីពីការលក់កុមារ ដូចបានកំណត់ក្នុងមាត្រា២ :

(i) រាល់ការប្រគល់ ការបញ្ជូន ឬការយកកុមារ ទោះតាមមធ្យោបាយណាក៏ដោយ ក្នុងបំណង :

ក. ធ្វើអាជីវកម្មខាងផ្លូវភេទលើកុមារ

ខ. ផ្ទេរសរីរាង្គកុមារ ដើម្បីយកកម្រៃ

គ. ដាក់កុមារឱ្យធ្វើការងារដោយបង្ខំ

(ii) ការអូសទាញឱ្យយល់ព្រមលើសុំកូនដោយមិនត្រឹមត្រូវ ក្នុងនាមជាអន្តរការី ដោយរំលោភលើលិខិតុបករណ៍គតិយុត្តិអន្តរជាតិ ស្តីពីការសុំកូនដែលកំពុងអនុវត្ត។

(ខ) ការឱ្យ ការទទួល ការធ្វើសញ្ជារកម្ម ឬការផ្គត់ផ្គង់កុមារសម្រាប់ពេស្យាកម្មកុមារ ដូចបានកំណត់ក្នុងមាត្រា២ ។

(គ) ការផលិត ការចែកចាយ ការផ្សព្វផ្សាយ ការនាំចូល ការនាំចេញ ការឱ្យ ការលក់ ឬការកាន់កាប់ សម្រាប់គោលបំណងខាងលើនូវអំពើអាសអាភាសកុមារដូចបានកំណត់ក្នុងមាត្រា២។

(២) ដោយស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ជាតិរបស់រដ្ឋភាគី បទប្បញ្ញត្តិដូចគ្នានេះ ត្រូវអនុវត្តចំពោះការប៉ុនប៉ងប្រព្រឹត្តអំពើណាមួយ ដូចបានរៀបរាប់ខាងលើ ព្រមទាំងចំពោះការសមគំនិត ឬការចូលរួមប្រព្រឹត្តអំពើណាមួយដូចបានរៀបរាប់ខាងលើ។

(៣) រដ្ឋភាគីនីមួយៗ ត្រូវដាក់បទល្មើសទាំងនោះ ជាបទល្មើសអាចផ្តន្ទាទោសបាន សមស្របទៅនឹងចរិតធ្ងន់ធ្ងរនៃបទល្មើស។

(៤) ដោយស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ជាតិរបស់ខ្លួន រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការតាមការចាំបាច់ ដើម្បីកំណត់កាតព្វកិច្ចទទួលខុសត្រូវរបស់នីតិបុគ្គល ចំពោះបទល្មើសដូចមានកំណត់ក្នុងកថាខណ្ឌ១ នៃមាត្រានេះ។ ដោយស្ថិតក្រោមគោលការណ៍គតិយុត្តិនៃរដ្ឋភាគី កាតព្វកិច្ចទទួលខុសត្រូវរបស់នីតិបុគ្គល អាចមានខាងព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬខាងរដ្ឋបាល។

(៥) រដ្ឋភាគី ត្រូវចាត់រាល់វិធានការសមស្របតាមផ្លូវច្បាប់ និងរដ្ឋបាល ដើម្បីធានាថា បុគ្គលគ្រប់រូបពាក់ព័ន្ធនឹងសុំកូន អនុវត្តស្របតាមបទបញ្ញត្តិនៃលិខិតុបករណ៍គតិយុត្តិអន្តរជាតិដែលកំពុងអនុវត្ត។

### មាត្រា ៤

១. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួន លើបទល្មើសដូចមានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា៣ បើបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តលើដែនដីរបស់រដ្ឋភាគី ឬលើនាវា ឬយន្តហោះដែលចុះបញ្ជីនៅក្នុងរដ្ឋនោះ។

២. រដ្ឋភាគីនីមួយៗ អាចចាត់វិធានការចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួន គ្រប់គ្រងបទល្មើស ដូចមានយោងក្នុងកថាខណ្ឌទី១ នៃមាត្រា៣ ក្នុងករណីដូចខាងក្រោម :

(ក) បើជនជាប់សង្ស័យនៃបទល្មើស ជាជនជាតិរបស់រដ្ឋនោះ ឬជាជនមានលំនៅដ្ឋានជាប់លាប់លើទឹកដីរបស់រដ្ឋនោះ។

(ខ) បើជនរងគ្រោះ ជាជនជាតិរបស់រដ្ឋនោះ។

៣. រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការចាំបាច់ដូចគ្នានេះផងដែរ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួន គ្រប់គ្រងបទល្មើសដូចបានបញ្ជាក់ខាងលើ បើជនជាប់សង្ស័យនៃបទល្មើស មានវត្តមានលើដែនដីរបស់រដ្ឋភាគី ហើយរដ្ឋភាគីមិនធ្វើបត្យាប័នជនជាប់សង្ស័យនេះទៅរដ្ឋភាគីផ្សេងទៀត ដោយមូលហេតុថាបទល្មើសត្រូវបានប្រព្រឹត្តដោយជនជាតិណាម្នាក់របស់ខ្លួន។

៤. ពិធីសារនេះ មិនផាត់ចេញនូវយុត្តាធិការព្រហ្មទណ្ឌណាមួយដែលត្រូវអនុវត្តស្របតាមច្បាប់ផ្ទៃក្នុងរបស់ខ្លួនទេ។

### មាត្រា ៥

១. បទល្មើសដូចចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៣ ត្រូវចាត់បញ្ចូលជាបទល្មើសដែលអាចធ្វើបត្យាប័ន ក្នុងសន្ធិសញ្ញាបត្យាប័នណាមួយដែលមានរវាងរដ្ឋភាគី និងត្រូវបញ្ចូលជាបទល្មើស ដែលអាចធ្វើបត្យាប័នបានក្នុងគ្រប់សន្ធិសញ្ញាបត្យាប័ន ដែលបានចុះកិច្ចសន្យារវាងរដ្ឋភាគី ស្របតាមលក្ខខណ្ឌបញ្ញត្តិក្នុងសន្ធិសញ្ញានោះ។

២. បើរដ្ឋភាគីដែលធ្វើបត្យាប័នកំណត់តាមអត្ថិភាពនៃសន្ធិសញ្ញាមួយបាន ទទួលការស្នើសុំបត្យាប័នពីរដ្ឋភាគីមួយទៀតដែលមិនមានសន្ធិសញ្ញាបត្យាប័ន ជាមួយគ្នា រដ្ឋនោះ អាចចាត់ទុកពិធីសារនេះ ជាមូលដ្ឋានគតិយុត្តិសម្រាប់ធ្វើ បត្យាប័នចំពោះបទល្មើសនោះ។ ការធ្វើបត្យាប័ន ត្រូវស្ថិតក្រោមលក្ខខណ្ឌ បញ្ញត្តិដែលកំណត់ដោយច្បាប់របស់រដ្ឋដែលទទួលពាក្យសុំ។

៣. រដ្ឋភាគី ដែលមិនធ្វើបត្យាប័នកំណត់តាមអត្ថិភាពនៃសន្ធិសញ្ញាណា មួយ ត្រូវទទួលស្គាល់បទល្មើសទាំងនោះ ជាបទល្មើសដែលអាចធ្វើបត្យាប័ន រវាងរដ្ឋភាគី អាស្រ័យតាមលក្ខខណ្ឌបញ្ញត្តិ ដែលកំណត់ដោយច្បាប់របស់រដ្ឋ ដែលទទួលការស្នើសុំ។

៤. ដើម្បីធ្វើបត្យាប័នរវាងរដ្ឋភាគី បទល្មើសទាំងនោះត្រូវចាត់ទុកថាបាន ប្រព្រឹត្ត មិនត្រឹមតែនៅកន្លែងកើតបទល្មើសប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងទឹកដី របស់រដ្ឋដែលបានកំណត់ជាយុត្តាធិការនៃរដ្ឋនោះ ស្របតាមមាត្រា៤ ។

៥. បើការស្នើសុំបត្យាប័នត្រូវបានធ្វើចំពោះបទល្មើសដូចចែងក្នុងកថា ខណ្ឌទី១ នៃមាត្រា៣ ហើយរដ្ឋភាគីដែលទទួលការស្នើសុំមិនធ្វើបត្យាប័ន ឬ នឹងមិនធ្វើបត្យាប័ន ដោយមកពីសញ្ជាតិរបស់ចារីនៃបទល្មើស រដ្ឋនោះត្រូវ ចាត់វិធានការសមស្រប ដើម្បីប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បី ធ្វើការចោទប្រកាន់។

## មាត្រា ៦

១. រដ្ឋភាគី ត្រូវចាត់វិធានការជួយគ្នាទៅវិញទៅមកឱ្យបានទូលំទូលាយ បំផុត ទាក់ទងនឹងការស៊ើបអង្កេត ឬនីតិវិធីខាងព្រហ្មទណ្ឌ ឬនីតិវិធីធ្វើបត្យា ប័ន ចំពោះបទល្មើស ដូចមានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា៣ រួមមាន ការជួយផ្តល់ភស្តុតាងដែលខ្លួនមាន និងដែលចាំបាច់សម្រាប់ដំណើរការក្តី។

២. រដ្ឋភាគីត្រូវអនុវត្តកាតព្វកិច្ចក្រោមកថាខណ្ឌទី១ នៃមាត្រានេះ ស្រប តាមសន្ធិសញ្ញា ឬការរៀបចំចាត់ចែងជួយគ្នាទៅវិញទៅមកតាមផ្លូវច្បាប់ដែល អាចមានរវាងគ្នានិងគ្នា។ បើគ្មានសន្ធិសញ្ញា ឬការរៀបចំចាត់ចែងទាំងនោះទេ រដ្ឋភាគីត្រូវជួយគ្នាទៅវិញទៅមកដោយយោងតាមច្បាប់ក្នុងប្រទេសរៀងខ្លួន។

## មាត្រា ៧

ស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ជាតិរបស់ខ្លួន រដ្ឋភាគីត្រូវ :

(ក) ចាត់វិធានការដែលយល់ថាសមស្រប ដើម្បីឃាត់ទុកឬរឹបអូសនូវ:

(i) ទំនិញ ដូចជា សម្ភារៈ ទ្រព្យ និងមធ្យោបាយខាងសម្ភារៈផ្សេង ទៀតដែលយកមកប្រើ ដើម្បីប្រព្រឹត្តបទល្មើស ឬសម្រួលដល់ការប្រព្រឹត្ត បទល្មើស ដូចមានចែងក្នុងពិធីសារនេះ។

(ii) ផលនៃបទល្មើស។

(ខ) អនុវត្តការស្នើសុំពីរដ្ឋភាគីម្ខាងទៀត ដើម្បីឃាត់ទុក ឬរឹបអូស ទ្រព្យ ឬផលនៃបទល្មើសដែលមានចែងក្នុងវាក្យខណ្ឌ(i) និងវាក្យខណ្ឌ(ii) នៃកថាខណ្ឌ(ក)។

(គ) ចាត់វិធានការបិទជាបណ្តោះអាសន្ន ឬជាស្ថាពរ នូវទីតាំងទាំង ឡាយដែលត្រូវបានប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសទាំងនោះ។

## មាត្រា ៨

១. រដ្ឋភាគី ត្រូវអនុម័តវិធានការសមស្របដើម្បីការពារសិទ្ធិ និងផល ប្រយោជន៍កុមាររងគ្រោះ ដោយសារការអនុវត្តដែលហាមឃាត់ក្នុងពិធីសារ នេះ នៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ ជាពិសេស ដោយៈ

(ក) ការទទួលស្គាល់ភាពងាយរងគ្រោះនៃកុមាររងគ្រោះនិងការសម្រប សម្រួលនីតិវិធី ដើម្បីទទួលស្គាល់តម្រូវការពិសេសរបស់កុមារ ជាអាទិ៍តម្រូវការពិសេសរបស់កុមារក្នុងការធ្វើជាសាក្សី។

(ខ) ការប្រាប់កុមាររងគ្រោះអំពីសិទ្ធិ តួនាទីរបស់ពួកគេ និងវិសាលភាព កាលវិភាគ និងការវិវត្តទៅមុខនៃនីតិវិធី និងអំពីចំណាត់ការរឿងក្ដីរបស់កុមារនោះ។

(គ) អនុញ្ញាតឱ្យមានការបង្ហាញ និងការពិចារណាអំពីទស្សនៈ សេចក្ដីត្រូវការ និងកង្វល់របស់កុមាររងគ្រោះ ក្នុងនីតិវិធីដែលប៉ះពាល់ដល់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់កុមារ ដោយឱ្យស្របតាមបទប្បញ្ញត្តិនៃនីតិវិធីច្បាប់ជាតិ។

(ឃ) ផ្ដល់សេវាគាំទ្រសមស្របចំពោះកុមាររងគ្រោះនៅគ្រប់ដំណាក់កាលនៃនីតិវិធីខាងផ្លូវច្បាប់។

(ង) ការពារជីវិតឯកជន និងអត្តសញ្ញាណរបស់កុមាររងគ្រោះឱ្យបានសមស្រប និងចាត់វិធានការស្របតាមច្បាប់ជាតិ ជៀសវាងការផ្សព្វផ្សាយព័ត៌មានមិនសមស្របដែលនាំឱ្យស្គាល់អត្តសញ្ញាណរបស់កុមាររងគ្រោះ។

(ច) ក្នុងករណីសមស្រប ផ្ដល់សុវត្ថិភាពដល់កុមាររងគ្រោះ ព្រមទាំងគ្រួសាររបស់កុមាររងគ្រោះ និងសាក្សីដាក់បន្ទុកឱ្យផុតពីការបំភិតបំភ័យ និងការសងសឹក។

(ឆ) ជៀសវាងការយឺតយ៉ាវដោយមិនចាំបាច់ ក្នុងចំណាត់ការរឿងក្ដី និងការអនុវត្តដីកា ឬសេចក្ដីសម្រេចផ្ដល់សំណងចំពោះកុមាររងគ្រោះ។

២. រដ្ឋភាគីត្រូវធានាថា មន្ទិលសង្ស័យអំពីអាយុពិតរបស់ជនរងគ្រោះ មិនរារាំងដល់ការផ្តើមស៊ើបអង្កេតព្រហ្មទណ្ឌ រួមទាំងការស៊ើបអង្កេត ដើម្បីកំណត់អាយុជនរងគ្រោះឡើយ។

៣. រដ្ឋភាគី ត្រូវចាត់វិធានការដើម្បីធានាថា ការប្រព្រឹត្តដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកុមារដែលរងគ្រោះពីបទល្មើស ដូចមានចែងក្នុងពិធីសារនេះ ត្រូវគិតជាចម្បងដល់ឧត្តមប្រយោជន៍របស់កុមារ។

៤. រដ្ឋភាគី ត្រូវចាត់វិធានការ ដើម្បីធ្វើការបណ្តុះបណ្តាលសមស្របជាពិសេស ការបណ្តុះបណ្តាលផ្នែកច្បាប់ និងចិត្តសាស្ត្រដល់ជនទាំងឡាយដែលធ្វើការជាមួយជនរងគ្រោះពីបទល្មើសដែលហាមឃាត់ក្នុងពិធីសារនេះ។

៥. រដ្ឋភាគី ក្នុងករណីសមស្រប ត្រូវអនុម័តវិធានការ ដើម្បីការពារសុវត្ថិភាព និងបូរណភាពរបស់ជនទាំងឡាយ និង/ឬអង្គការដែលពាក់ព័ន្ធក្នុងការងារបង្ការ និង/ឬការពារ និងស្តារនីតិសម្បទាជនរងគ្រោះនៃបទល្មើសទាំងនេះ។

៦. គ្មានបទប្បញ្ញត្តិណាមួយនៃមាត្រានេះ ត្រូវបានបកស្រាយថា ជាការប៉ះពាល់ ឬមានវិសមភាពនឹងសិទ្ធិរបស់ជនជាប់ចោទ ចំពោះការជំរះក្តីមួយដែលមិនលំអៀង និងយុត្តិធម៌ឡើយ។

### មាត្រា ៩

១. រដ្ឋភាគីត្រូវអនុម័ត ឬពង្រឹង អនុវត្ត និងផ្សព្វផ្សាយច្បាប់ វិធានការរដ្ឋបាល គោលនយោបាយ និងកម្មវិធីសង្គម ដើម្បីបង្ការបទល្មើស ដូចមានចែងក្នុងពិធីសារនេះ។ រដ្ឋភាគីត្រូវផ្តល់ ការយកចិត្តទុកដាក់ជាពិសេសដល់ការការពារកុមារដែលងាយរងគ្រោះបំផុតពីការអនុវត្តទាំងនោះ។

២. រដ្ឋភាគី ត្រូវលើកកំពស់ការយល់ដឹង ដល់សាធារណៈជនទាំងអស់ រួមមាន កុមារផង តាមរយៈការផ្សព្វផ្សាយព័ត៌មាន តាមគ្រប់មធ្យោបាយសមស្រប ការអប់រំ និងការបណ្តុះបណ្តាលអំពីវិធានការបង្ការ និងអំពីឥទ្ធិពលប្រកបដោយគ្រោះថ្នាក់នៃបទល្មើសដូចចែងក្នុងពិធីសារនេះ។ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមមាត្រានេះ រដ្ឋភាគី ត្រូវជំរុញឱ្យមានការចូលរួមពីសហគមន៍ និងជាពិសេស កុមារ និងកុមាររងគ្រោះក្នុងកម្មវិធីព័ត៌មាន អប់រំ និងបណ្តុះបណ្តាល រួមមាននៅថ្នាក់អន្តរជាតិផង។

៣. រដ្ឋភាគីត្រូវចាត់វាល់វិធានការដែលអាចធ្វើបាន សំដៅធានាឱ្យមានគ្រប់ជំនួយសមស្រប ដល់ជនរងគ្រោះនៃបទល្មើសទាំងនោះ រួមមាន ការធ្វើសមាហរណកម្មពេញលេញ នៃជនទាំងនោះទៅក្នុងសង្គម និងការស្តារសម្បទាខាងរាងកាយ និងខាងផ្លូវចិត្ត នៃកុមារទាំងនោះផង។

៤. រដ្ឋភាគីត្រូវធានាថា កុមាររងគ្រោះនៃបទល្មើសដូចមានចែងក្នុងពិធីសារនេះ មានសិទ្ធិទទួលបាននីតិវិធីគ្រប់គ្រាន់ ដោយមិនរើសអើង ដើម្បីទទួលបានសំណងលើការខូចខាត ពីជនទាំងឡាយដែលទទួលខុសត្រូវតាមផ្លូវច្បាប់។

៥. រដ្ឋភាគីត្រូវចាត់វិធានការសមស្រប សំដៅហាមឃាត់ប្រកបដោយប្រសិទ្ធភាពនូវការផលិត និងការផ្សព្វផ្សាយសម្ភារៈដែលផ្សាយពាណិជ្ជកម្មពីបទល្មើសដូចមានកំណត់ក្នុងពិធីសារនេះ។

### មាត្រា ១០

១. រដ្ឋភាគីចាត់វាល់វិធានការចាំបាច់ ដើម្បីពង្រឹងសហប្រតិបត្តិការអន្តរជាតិ តាមការព្រមព្រៀងពហុភាគី ថ្នាក់តំបន់ និងទ្វេភាគី ដើម្បីបង្ការ ស្វែងរក

ស៊ើបអង្កេត ចោទប្រកាន់ និងផ្តន្ទាទោសជនដែលទទួលខុសត្រូវចំពោះអំពើពាក់ព័ន្ធការលក់កុមារ ពេស្យាកម្មកុមារ រូបភាពឬសម្ភារៈអាសអាភាសកុមារ និងទេសចរណ៍ផ្លូវភេទកុមារ។ រដ្ឋភាគីត្រូវលើកស្ទួយផងដែរនូវសហប្រតិបត្តិការ និងការសម្របសម្រួលអន្តរជាតិ រវាងអាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងអង្គការអន្តរជាតិ។

២. រដ្ឋភាគីត្រូវលើកស្ទួយសហប្រតិបត្តិការអន្តរជាតិ ដើម្បីជួយកុមាររងគ្រោះក្នុងការស្តារសម្បទាខាងផ្លូវកាយ និងផ្លូវចិត្ត ការធ្វើសមាហរណកម្មទៅក្នុងសង្គម និងការធ្វើមាតុភូមិនិវត្តន៍។

៣. រដ្ឋភាគី ត្រូវពង្រឹងសហប្រតិបត្តិការអន្តរជាតិ ដើម្បីដោះស្រាយមូលហេតុជាឬសគល់ ដូចជា ភាពក្រីក្រ និងភាពឱនថយ ដែលរួមចំណែកឱ្យកុមារងាយរងគ្រោះ ពីការលក់កុមារ ពេស្យាកម្មកុមារ រូបភាពឬសម្ភារៈអាសអាភាស និងទេសចរណ៍ផ្លូវភេទកុមារ។

៤. រដ្ឋភាគី ដែលមានលទ្ធភាពធ្វើទៅបាន ត្រូវផ្តល់ជំនួយហិរញ្ញវត្ថុ បច្ចេកទេស ឬជំនួយផ្សេងទៀត តាមរយៈកម្មវិធីពហុភាគី ថ្នាក់តំបន់ ទ្វេភាគី ឬកម្មវិធីផ្សេងទៀតដែលអាចមាន។

## មាត្រា ១១

គ្មានបទប្បញ្ញត្តិណាមួយនៃពិធីសារនេះ ប៉ះពាល់ដល់បទបញ្ញត្តិទាំងឡាយ ដែលនាំឱ្យសម្រេចបាននូវសិទ្ធិកុមារប្រសើរជាងនេះ ដែលអាចមានចែងក្នុង៖

(ក) ច្បាប់របស់រដ្ឋភាគី និង

(ខ) ច្បាប់អន្តរជាតិដែលចូលជាធរមានសម្រាប់រដ្ឋនោះឡើយ។

### មាត្រា ១២

១. រដ្ឋភាគីនីមួយៗ ក្នុងរយៈពេល ២ឆ្នាំ ចាប់ពីពិធីសារនេះចូលជាធរមានសម្រាប់រដ្ឋនោះ ត្រូវដាក់របាយការណ៍ជូនគណៈកម្មាធិការសិទ្ធិកុមារ ដោយផ្តល់ព័ត៌មានទូលំទូលាយលើវិធានការនានារបស់រដ្ឋភាគី ក្នុងការអនុវត្តបទប្បញ្ញត្តិនៃពិធីសារនេះ។

២. បន្ទាប់ពីដាក់ជូនរបាយការណ៍ទូលំទូលាយហើយ រដ្ឋភាគីនីមួយៗ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍នានារបស់ខ្លួន ជូនទៅគណៈកម្មាធិការសិទ្ធិកុមារ ស្របតាមមាត្រា៤៤ នៃអនុសញ្ញា នូវព័ត៌មានបន្ថែម ទាក់ទងនឹងការអនុវត្តពិធីសារនេះ។ រដ្ឋភាគីផ្សេងទៀតនៃពិធីសារនេះ ត្រូវធ្វើរបាយការណ៍រៀងរាល់ ៥ឆ្នាំម្តង។

៣. គណៈកម្មាធិការសិទ្ធិកុមារ អាចស្នើសុំឱ្យរដ្ឋភាគីផ្តល់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការអនុវត្តពិធីសារនេះ។

### មាត្រា ១៣

១. ពិធីសារនេះបើកឱ្យរដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ឬរដ្ឋដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ចុះហត្ថលេខា។

២. ពិធីសារនេះ ជាកម្មវត្ថុឱ្យសច្ចាប័ន និងបើកឱ្យសុំចូលជាសមាជិកចំពោះរដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ឬរដ្ឋដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។ លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

### មាត្រា ១៤

១. ពិធីសារនេះចូលជាធរមានក្នុងរយៈពេល៣ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកទី១០។

២. ចំពោះរដ្ឋនីមួយៗដែលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកបន្ទាប់ពីពិធីសារនេះចូលជាធរមាន ពិធីសារនេះ ត្រូវចូលជាធរមានក្នុងរយៈពេល១ខែ បន្ទាប់ពីកាលបរិច្ឆេទ នៃការតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬសុំចូលជាសមាជិករបស់រដ្ឋនោះ។

## មាត្រា ១៥

១. រដ្ឋភាគីអាចប្រកាសដកខ្លួនចេញពីពិធីសារនេះបានគ្រប់ពេល ដោយការជូនដំណឹងជាលាយល័ក្ខអក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការត្រូវជូនដំណឹងពីការប្រកាសដកខ្លួននេះ ទៅរដ្ឋភាគីផ្សេងទៀតនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ការប្រកាសដកខ្លួនមាន អនុភាពក្នុងរយៈពេល១ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបានការជូនដំណឹង។

២. ការប្រកាសដកខ្លួននេះ ពុំមានអានុភាពឱ្យរដ្ឋភាគីរួចផុតពីកាតព្វកិច្ចរបស់ខ្លួន ក្រោមពិធីសារនេះ ចំពោះបទល្មើសណាដែលកើតមុនកាលបរិច្ឆេទនៃការប្រកាសដកខ្លួន ចូលជាធរមានឡើយ។ ទោះតាមមធ្យោបាយណាក៏ដោយ ការប្រកាសដកខ្លួននេះ មិនប៉ះពាល់ដល់ការបន្តពិនិត្យបញ្ហាទាំងឡាយ ដែលគណៈកម្មាធិការសិទ្ធិកុមារកំពុងពិនិត្យ មុនកាលបរិច្ឆេទប្រកាសដកខ្លួនចូលជាធរមានឡើយ។

## មាត្រា ១៦

១. រដ្ឋភាគីអាចសុំធ្វើវិសោធនកម្ម និងដាក់សេចក្តីស្នើសុំនេះ ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការ ត្រូវបញ្ជូនសេចក្តីស្នើវិសោធនកម្មទៅរដ្ឋភាគី ដោយស្នើសុំឱ្យរដ្ឋភាគីបញ្ជាក់ថាតើរដ្ឋភាគីយល់ព្រម

ឱ្យមានសន្និសីទនៃរដ្ឋភាគីទាំងអស់ ដើម្បីពិនិត្យ និងបោះឆ្នោតលើសេចក្តីស្នើសុំឬទេ។ ក្នុងរយៈពេល៤ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការឆ្លើយឆ្លងនោះក្នុងករណីមានសំឡេង១ភាគ៣យ៉ាងតិចនៃរដ្ឋភាគី គាំទ្រឱ្យមានសន្និសីទបែបនេះ អគ្គលេខាធិការត្រូវកោះធ្វើសន្និសីទ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ វិសោធនកម្មដែលបានអនុម័តដោយមតិភាគច្រើន នៃរដ្ឋភាគីវត្តមាន និងបានបោះឆ្នោតក្នុងសន្និសីទ ត្រូវដាក់ជូនមហាសន្និបាតសហប្រជាជាតិដើម្បីសុំការយល់ព្រម។

២. វិសោធនកម្មដែលបានអនុម័តស្របតាមកថាខណ្ឌទី១ នៃមាត្រានេះត្រូវចូលជាធរមាន នៅពេលវិសោធនកម្មនេះទទួលបានការយល់ព្រមពីមហាសន្និបាត និងបានទទួលយកដោយមតិភាគច្រើន២ភាគ៣នៃរដ្ឋភាគី ។

៣. នៅពេលវិសោធនកម្មចូលជាធរមានហើយ វិសោធនកម្មនោះ នឹងក្លាយជាកាតព្វកិច្ច សម្រាប់រដ្ឋភាគីដែលយល់ព្រមទទួលយកវិសោធនកម្មនោះ រដ្ឋភាគីក្រៅពីនេះ នៅតែជាប់កាតព្វកិច្ចចំពោះបទប្បញ្ញត្តិនៃពិធីសារនេះ និងវិសោធនកម្មមុនៗ ដែលរដ្ឋភាគីនោះបានយល់ព្រមទទួលយក។

### មាត្រា ១៧

១. ពិធីសារនេះ ដែលមានអត្ថបទជាភាសាអារ៉ាប់ អង់គ្លេស បារាំង ចិន រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតម្លៃយថាភូតស្មើគ្នា និងត្រូវដំកល់ទុកនៅបណ្ណសារដ្ឋាននៃអង្គការសហប្រជាជាតិ។

២. អគ្គលេខាធិការសហប្រជាជាតិត្រូវបញ្ជូនសេចក្តីចម្លងនៃពិធីសារនេះ ដោយមានបញ្ជាក់ការចម្លងស្របតាមច្បាប់ដើម ជូនរដ្ឋភាគីទាំងអស់នៃអនុសញ្ញា និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ។